# សេចក្តីសង្ខេបប្រតិបត្តិ
(Executive Summary)

## ១. សេចក្តីផ្តើម

ក្នុងគោលដៅស្រូបយកផលប្រយោជន៍ដ៏សំបូរបែប ដែលជាអំណោយផលធម្មជាតិរបស់កម្ពុជា និងក្នុងគោលដៅចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជាកាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើនការអភិវឌ្ឍសេដ្ឋកិច្ចលើគ្រប់វិស័យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនេះ ទើបសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០៧ បានអនុម័តជាឯកច្ឆន្ទ លើគំរោងអភិវឌ្ឍន៍វារីអគ្គិសនីអាតៃ និងគំរោងប្រព័ន្ធខ្សែបញ្ជូនតភ្ជាប់ភ្នំពេញ-កំពង់ឆ្នាំង-ពោធិ៍សាត់-បាត់ដំបង និងអនុស្ថានីយទៅឱ្យក្រុមហ៊ុន C.H.D (Cambodia) Hydropower Development ។ បន្ទាប់មកអគ្គនាយកក្រុមហ៊ុនអគ្គិសនីកម្ពុជាបានស្នើសុំការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជាដើម្បីចុះហត្ថលេខា លើកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជាជាមួយក្រុមហ៊ុន China Yunnan Corporation for International Techno-Economic Cooperation(CYC) និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជាជាមួយក្រុមហ៊ុន Yunan Southeast-Asia Economy and Technology Investment Industrial Co., Ltd លិខិតនេះត្រូវបានយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជានៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ និងទទួលការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ។

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ ដដែលនេះ រាជរដ្ឋាភិបាល បានប្រទានសិទ្ធិជូនឯកឧត្តម **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង IMPLEMENTATION AGREEMENT (IA) លើកិច្ចព្រមព្រៀង LEASE AGREEMENT (LA) និងលើលិខិតធានាទូរទាត់របស់រាជរដ្ឋាភិបាលនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ( FORM OF GOVERNMENT GUARANTEE OF PAYMENT ) ដោយក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) ទៅឱ្យក្រុមហ៊ុន China Yunnan Corporation for International Techno-Economic Cooperation (CYC)សំរាប់គំរោងវារីអគ្គិសនី ស្ទឹងអាតៃខេត្តពោធិ៍សាត់ដែលមានកំលាំង១២០ MW ។

Draft

គំរោងវារីអគ្គិសនីស្ទឹងអាតៃអាចមានលទ្ធភាពផលិតថាមពលអគ្គិសនីបានប្រមាណ ១២០ MW ហើយត្រូវការរយៈពេលសាងសង់០៤ឆ្នាំ ( ចាប់ផ្តើមសាងសង់ពីខែវិច្ឆកា ឆ្នាំ២០០៩ និងបញ្ចប់នៅខែវិច្ឆកា ឆ្នាំ២០១៣) ។ គំរោងនេះមានតំលៃវិនិយោគសរុប ២៨៦.៨៨៥.៦០០ (ពីររយសែសិបប្រាំមួយលាន ប្រាំបីរយប៉ែតសិបប្រាំពាន់ ប្រាំមួយរយដុល្លារអាមេរិក) ដុល្លារអាមេរិក ក្នុងនោះទុនវិនិយោគសំរាប់ប្រព័ន្ធខ្សែចម្លង១១៥ គ.វ ៣៧.០២៧.១០០ (សាមសិបប្រាំពីរលាន ម្ភៃប្រាំពីរពាន់ ប្រាំមួយរយ) ដុល្លារអាមេរិក ។

## ២. វិធីសាស្ត្រនៃការសិក្សា

ចំណុចសំខាន់ៗនៃវិធីសាស្ត្រក្នុងការសិក្សាលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) របស់គំរោងវិនិយោគទុនលើវិស័យវារីអគ្គិសនីស្ថិតនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ របស់ក្រុមហ៊ុន C.H.D (Cambodia) Hydropower Development ។ មានយន្តការនៃវិធីសាស្ត្រសិក្សាធនធានបរិស្ថានទាំងបីគឺ បរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងបរិស្ថានសេដ្ឋកិច្ច-សង្គម បានធ្វើឡើងរួមមានដូចតទៅ:

- ប្រមូលទិន្នន័យ និងព័ត៌មានដែលទាក់ទងជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់នៅភ្នំពេញដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងបរិស្ថាន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងផែនការ, NGOs ,សាមីក្រុមហ៊ុន និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ។
- ការចុះប្រមូលទិន្នន័យដល់ទីតាំងភូមិសាស្ត្ររបស់គំរោង និងមានការប្រឹក្សាពិគ្រោះយោបល់ពីសាធារណជន, មេភូមិ, មេឃុំ, អភិបាលស្រុក និងស្ថាប័នពាក់ព័ន្ធដូចជា មន្ទីឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត, មន្ទីរកសិកម្មខេត្ត, មន្ទីរបរិស្ថានខេត្ត, មន្ទីរធនធានទឹកខេត្ត, មន្ទីរដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត, ខណ្ឌរដ្ឋបាលព្រៃឈើ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) មួយចំនួន ។ (សូមពិនិត្យមើលជំពូក៦ កំណត់ហេតុ)
- ការចុះអង្កេតសិក្សាពីបរិស្ថានធម្មជាតិដោយផ្ទាល់លើទីតាំងគំរោង ដូចជាការសិក្សាប្រព័ន្ធជលសាស្ត្រ, ភូគព្ភសាស្ត្រ និងដី, ព្រៃឈើ, សត្វព្រៃ, មច្ឆជាតិ ។ល ។ ដោយមានការបង្ហាញពីអ្នកភូមិផ្ទាល់ ។
- ការចុះអង្កេតសិក្សារកដីដែលប្រើប្រាស់ (ដីប៉ះពាល់) របស់ប្រជាពលរដ្ឋក្នុងតំបន់ទីតាំងគំរោង ។
- ការចុះសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលមានដីប៉ះពាល់ក្នុងតំបន់អភិវឌ្ឍន៍គំរោង ។
- ការយកគំរូសាក និងធ្វើការវិភាគលើគុណភាពទឹកផ្ទាល់នៅប្រភពធនធានទឹកលើដី និងក្រោមដី (សូមពិនិត្យ មើលតារាង តេស្តទឹកនៅទីកន្លែងផ្ទាល់របស់គំរោងក្នុងឧបសម្ព័ន្ធ២) ដើម្បីរកកំរិតគុណភាពប្រភពទឹកដើមមុនការអភិវឌ្ឍគំរោង ។
- ធ្វើការវិភាគទិន្នន័យទាំងអស់ដែលប្រមូលបាន និងរៀបរាប់អំពីស្ថានភាពបរិស្ថានធម្មជាតិ និងសង្គមដែលមានស្រាប់រួចធ្វើការប៉ាន់ប្រមាណពីស្ថានភាពបរិស្ថានទាំងនោះ ដែលអាចកើតមានឡើងនៅក្នុងកំឡុងពេលរចនាប្លង់សាងសង់, ប្រតិបត្តិ និងថែទាំ និងបញ្ចប់គំរោង ។
- ពិនិត្យ និងសំរួលឡើងវិញនូវផែនការមេរបស់គំរោង ។
- កំណត់ទំហំឥទ្ធិពលហេតុប៉ះពាល់អវិជ្ជមាន និងវិជ្ជមានដែលបណ្តាលមកពីសកម្មភាពរបស់គំរោង ។ រិះរកវិធានការលើកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានឱ្យដល់កំរិតអប្បបរមាហើយធ្វើឱ្យប្រសើរឡើងនូវហេតុប៉ះពាល់បរិស្ថានវិជ្ជមាន ឱ្យដល់កំរិតអតិបរមា ដោយដកស្រង់ពីការប្រឹក្សាជាសាធារណៈ និងសំណូមពរផ្សេងៗពីប្រជាពលរដ្ឋ និងស្ថាប័នដែលពាក់ព័ន្ធក្នុងតំបន់គំរោង ។
- រៀបចំផែនការគ្រប់គ្រងបរិស្ថាន Environmental Management Plan (EMP) ដោយមានដាក់កម្មវិធីត្រួតពិនិត្យ (Monitoring Program) នៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិ ថែទាំគំរោងទៀតផង ។

## ៣. ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

ដើម្បីធ្វើអោយគំរោងមានការអភិវឌ្ឍបានល្អ ក្របខ័ណ្ឌច្បាប់ចំនួន ៧ និងអនុក្រឹត្យចំនួន ៤ ដែលពាក់ពន្ធ័ដូចខាងក្រោម ត្រូវសិក្សា និងអនុវត្តន៍ ។

ក្របខណ្ឌច្បាប់មានដូចជា:

១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

២. ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

៣. ច្បាប់ភូមិបាល ឆ្នាំ២០០១

៤. ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២

៥. ច្បាប់ជលផល ឆ្នាំ ២០០៦

៦. ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ឆ្នាំ២០០៧

៧. ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៧

អនុក្រឹត្យមានដូចខាងក្រោម:

១. អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក

២. អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង

៣. អនុក្រឹត្យ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ ១៩៩៩

៤. អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ឆ្នាំ ២០០៣

## ៤. ការពិពណ៌នាអំពីគំរោង

ការផលិតថាមពលអគ្គិសនីរបស់គំរោងនេះគឺប្រើចរន្តទឹក ដែលនឹងសាងសង់ទំនប់ធ្វើអំពីបេតុងកាត់ស្ទឹងអាតៃ ដែលមានចំងាយប្រមាណ ៨៦ គ.ម. ពីទីរួមខេត្តកោះកុង និងប្រមាណ ១៦៨ គ.ម. ពីទីរួមខេត្តពោធិ៍សាត់ ដល់ការិយាល័យក្រុមហ៊ុននៅទំនប់ទី២ ។ ទំនប់ទាំងពីរនេះនឹងបង្កើតបានជាអាងទឹកពីរជាប់ៗគ្នា ហើយនៅក្រោមទំនប់អាងទឹកទី១ មានអគារថាមពលទី១ ដែលមានទួរប៊ីន២ (១០ MW ខ ២) កំលាំងសរុប ២០ MW ។ នៅក្រោមទំនប់ទី២ ចំងាយប្រមាណ ៥.៣៨០ម មានអគារថាមពលទី២ ដែលយកទឹកពីអាងទី២ តាមបំពង់ទូនេលបង្ហូរទឹកក្រោមដីដែលមានសម្ពាធខ្ពស់ភ្ជាប់ទៅទួរប៊ីន ៤ (២៥ MW x ៤) នៃអគារថាមពលទី២ ដែលមានកំលាំងសរុប ១០០ MW ។ ដើម្បីឱ្យគំរោងនេះមានដំណើរបាននោះ គំរោងនឹងសាងសង់ប្រព័ន្ធខ្សែបញ្ជូនចរន្តអគ្គិសនីតង់ស្យុងខ្ពស់ ១១៥គ.វ ពីអគារថាមពលទៅអនុស្ថានីយ៍អូរសោម ។

យោងទៅតាមកិច្ចព្រមព្រៀងអភិវឌ្ឍន៍ គំរោងវារីអគ្គិសនីស្ទឹងអាតៃនេះរវាងរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន CHD (Cambodia) Hydropower Development Co., Ltd ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៧ គំរោងនេះជាគំរោង សាងសង់ ដំណើរការប្រតិបត្តិ ហើយផ្ទេរ ( Stung Atay Hydro-Electric in Pursat Province, Cambodia (the Project) on Build-Operate-Transfer (BOT) basis) ដែលមានកំលាំងសរុប ***១២០ MW*** ។

តំបន់ដែលក្រុមហ៊ុន C.H.D (Cambodia) Hydropower Development Co., Ltd នឹងធ្វើការអភិវឌ្ឍន៍ វារីអគ្គិសនីមានទីតាំងស្ថិតនៅចំងាយប្រមាណ ៨៦ គីឡូម៉ែត្រភាគទក្សិណ ពីទីរួមខេត្តកោះកុង ហើយមានចំងាយប្រមាណ ១៦៨គីឡូម៉ែត្រដល់ទីតាំងការិយាល័យក្រុមហ៊ុននៅទំនប់ទី២ គឺស្ថិតនៅភាគនិរតី ពីទីរួមខេត្តពោធិ៍សាត់ ដែលស្ថិតក្នុងឃុំអូរសោម ស្រុកវាលវែង ត្រង់ចន្លោះខ្សែស្របទី ១១°57′ និង ១២°01′ នៃរយៈទទឹងខាងជើង និងខ្សែ បណ្តោយទី ១០៣°07′ និង ១០៣°12′ នៃរយៈបណ្តោយខាងកើត ។

កម្មវត្ថុទូទៅនៃការសាងសង់វារីអគ្គិសនី មានដូចខាងក្រោម :

- <u>**ផលិតកម្មចំបង**</u> : ថាមពលអគ្គិសនី ១២០ មេហ្គាវ៉ាត់៖
- ការកាត់បន្ថយទឹកជំនន់ នៅតំបន់ខាងក្រោមអាង និង បង្កើតតំបន់ទេសចរណ៍ធម្មជាតិ ។
- លៃតម្រូវការធារទឹករបស់ស្ទឹងអាតៃ នៅរដូវប្រាំង ។

ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់វារីអគ្គិសនីគឺ មានទំនប់ទប់ស្ទឹង២កន្លែងដែលបង្កើតជាអាងទឹក២ផងដែរ. ទូនេល (Tunnel) ១ខ្សែ ទៅអគារផលិតថាមពលអគ្គិសនីទី២. អគារផលិតថាមពល២កន្លែង. និងខ្សែបញ្ជូនចរន្តដែលមានតង់ស្យុងខ្ពស់



Draft

១១៥គវ ចំនួន ២ខ្សែ ភ្ជាប់ទៅអនុស្ថានីយ៍អូរសោម (វាលត្រង់ស្ទ័រនៅភូមិស្ទឹងតាចាន់ដែលទទួលខុសត្រូវដោយអគ្គិសនីកម្ពុជា និងក្រុមហ៊ុន Cambodian Power Grid) (មើលកូអរដោនេនៅជំពូកទី៤ ចំណុច ៤.៣) ។

## ៥. ស្ថានភាពបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គំរោង

តំបន់អាតៃនេះមានបរិមាណទឹកភ្លៀងធ្លាក់ខ្ពស់បង្គួរ បើប្រៀបទៅតំបន់ទំនាបកណ្ដាល ព្រោះវាស្ថិតនៅក្បែរតំបន់មាត់សមុទ្រ និងតំបន់ភ្នំជាប់ខេត្តកោះកុង នៃប្រទេសកម្ពុជា និងនៅជ្រលងនៃជួរភ្នំក្រវាញក្នុង ខេត្តពោធិ៍សាត់ ។ គ្មានទិន្នន័យទឹកភ្លៀងកត់ត្រានៅតំបន់គំរោងឡើយមានតែស្ថានីយ៍កត់ត្រាទឹកភ្លៀងដែលនៅជិតជាងគេនោះ គឺស្ថានីយ៍ស្មាច់មានជ័យ (ក្រុងខេមរភូមិន្ទ) ខេត្តកោះកុង ។ បរិមាណទឹកភ្លៀងធ្លាក់គិតជាមធ្យមរយៈពេល១២ឆ្នាំ គិតពីឆ្នាំ ១៩៩៩ ដល់ ២០១០ **គឺ ៤០៩៣.៦៨មម** (Return Period 12 years) (ប្រភពទិន្នន័យបានពីមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកុងកោះ) ។ **សីតុណ្ហភាពអតិបរមា** រយៈពេល ១៥ ឆ្នាំ ខ្ពស់បំផុតមានកំរិត ៣៥.៣°C នៅឆ្នាំ១៩៩៩ ។ សីតុណ្ហភាពអប្បបរមារយៈពេល ១៥ **ឆ្នាំទាបបំផុតមាន** កំរិត ២០.១°C នៅឆ្នាំ ២០១០ ។ មន្ទីរពិសោធន៍ នៃក្រសួងបរិស្ថាន បានចុះទៅវាស់គុណភាពខ្យល់ និងសំលេង **២៤ ម៉.** នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១១ នៅកន្លែងកិនថ្ម ដែលជាកន្លែងមានសកម្មភាពមមាញឹកជាងគេក្នុងតំបន់គំរោងបានបង្ហាញថា គុណភាពខ្យល់ស្ថិត នៅក្រោមកំរិត ស្តង់ដារបស់ក្រសួងបរិស្ថាននៅឡើយ ។ គ្មានការបំពុលណាមួយ ដោយសារសំលេង និងរំញ័រគួរឱ្យកត់សំគាល់ទេ ក្រៅពីសំលេង ម៉ូតូ រថយន្តតូច រទេះគោ គោយន្ត តិចតួចនៅតាមផ្លូវចេញ ចូលទៅឃុំ អូរសោម នៃស្រុកវាលវែង ព្រមទាំងសំលេង សត្វព្រៃស្រែក ដូចជាសត្វទោច បក្សីចកវែក ញ៉ាង ជាដើម ។៣។

តាមផែនទីប្រភេទដីរបស់លោក Crocker ឆ្នាំ ១៩៦៣ មាត្រដ្ឋាន ១/១.០០០.០០០ បានបង្ហាញថា តំរេដីផ្ទៃអាងដែលនឹងត្រូវលិច ៤២៣៧ ហ.ត នេះមានសមាសភាពដី ២ ប្រភេទគឺ ប្រភេទដី Acid Lithosols មានផ្ទៃដី ៣៨៩៥ ហិកតា និង Red-Yellow Podzols ៣៤២ ហិកតា ។

ផ្នែកខាងលើខាងលើនៃផ្ទៃរងទឹកភ្លៀង/វស់ស្ទឹងអាតៃស្ថិតផ្នែកមួយនៃជួរភ្នំដងរែកជាតំបន់ខ្ពង់រាប **និងតំបន់ភ្នំដែលមាន**សណ្ឋាន $Ii_2$ rvag Mawlamyine Grade IV នៃទំនាបភ្នំពេញ និង Mesozoic sag $LL_2^{4-2}$ Grade III **នៃពោធិ៍សាត់** ។ ចំពោះលក្ខណៈភូគព្ភសាស្ត្រគឺ Hercynian nig Indosinian ។ សកម្មភាពភ្នំភ្លើងបានបង្កើតកំអែលភ្នំភ្លើង **Magma**តិច ជាមួយនឹងការហូរគ្របដណ្ដប់ទៅលើសណ្ឋានដី Variscan នៃសម័យកកើត Indosinian-Yanshanian ក្នុងយុគ្គ Neogene Period – Pleistocene (Himalayan period) បង្កើតបានជាសិលាបាសាល ថ្មភក់ និងថ្មខ្សាច់នៃតំបន់ទាំងនោះ ។

យោងតាមទិន្នន័យរបស់ក្រុមហ៊ុន CHDដែលកត់ត្រាខ្វបរយៈពេល ៥ឆ្នាំពីឆ្នាំ ២០០៥ ដល់ ២០១០ នៅទីតាំងទំនប់ទី២ បានឱ្យដឹងថាធារទឹកអតិបរិមា ហើយច្រើនកើតមានជាងគេក្នុងមួយឆ្នាំ គឺនៅរដូវវស្សាខែ សីហា ៦០.៩ $ម^3/s$ **កញ្ញា** ៤១.២ $ម^3/s$ និងតុលា ៤៩.៤ $ម^3/s$ ។ ចំណែកឯនៅរដូវប្រាំងធារទឹកដែលតិចជាងគេច្រើនកើតឡើងនៅចន្លោះខែ មករា **១.២៨**$ម^3/s$ កុម្ភៈ ១.១ $ម^3/s$ និង មិនា ១.២៥ $ម^3/s$ (មើលតារាង ២៤) ។

នៅក្នុងតំបន់ផ្ទៃអាងដែលនឹងត្រូវលិចនេះ យោងតាមការសិក្សារបស់ក្រុមការងារ SAWAC **មានតែអាងទី១ប៉ុណ្ណោះ**ដែលមានដីស្រែចំការ(ដីកសិកម្ម) ដីលំនៅដ្ឋាន និងដីកប់ខ្មោចរបស់ប្រជាជនរស់នៅបីភូមិ ក្នុងឃុំអូរសោម ហើយដីកសិកម្មទាំងនោះពុំមានប្រព័ន្ធស្រោចស្រពទេ ។ សព្វថ្ងៃនេះប្រជាកសិករក្នុងតំបន់ពឹងផ្អែក លើទឹកភ្លៀងទាំងស្រុង ។

Draft

ក្រុមការងារបានចែកតំបន់គំរោងជាបីផ្នែកគឺតំបន់អាង (ទី១និងទី២) តំបន់សាងសង់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី និងតំបន់តាមគន្លងខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥ ។ ដូចបានពិពណ៌នាក្នុងជំពូក ២ វិធីសាស្ត្រនៃការសិក្សាព្រៃឈើ របស់ក្រុមការងារ SAWAC បានកំណត់តំបន់គំរោងនេះមានផ្ទៃដីសរុប **ចំនួន ៥.០៩៨.៦៨ ហ.ត** ក្នុងនោះមានផ្ទៃអាងទាំងពីរចំនួន ***៤.២៣៧ហ.ត*** តំបន់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីចំនួន ***៨១៣.២៣ហ.ត*** គន្លងខ្សែចម្លងតង់ស្យុងខ្ពស់ ១១៥ គ.វ ***៤៨.៤៤ហ.ត***។ លំអិតមានចែងក្នុងតារាង ៦ ក្នុងជំពូក ៤ ។

ចំពោះគំរបព្រៃឈើដែលមាននៅក្នុងតំបន់គំរោងមាន ៤.៦៧៥.១៧ ហ.ត ក្នុងនោះមានដីព្រៃឈើ ៤៨៧.៣៦ ហ.ត ដែលមិនបានកាប់ឆ្ការ ។ ដូចនេះគំរបព្រៃឈើប៉ះពាល់មានចំនួន៤.១៨៧.៨១ហ.ត ក្នុងនោះមានព្រៃស្រោង៣.៨៨៤.១២ ហិកតា, ព្រៃពាក់កណ្ដាលស្រោង ១១៩.៨ ហិកតា, ព្រៃល្បាយឫស្សី ៧០.៤៤ ហិកតា, ព្រៃគុម្ពោធ ១០៨.៤៥ ហិកតា, ព្រៃល្បាយស្រល់ ៥ ហិកតា។ មានសត្វព្រៃច្រើនប្រភេទរស់នៅក្នុងតំបន់គំរោងនេះ រួមមានថនិកសត្វចំនួន ៥០ប្រភេទ បក្សី ១៣០ ប្រភេទ ឧរង្គសត្វ ៣៦ប្រភេទ មច្ឆជាតិ ២១ប្រភេទ ។

ខេត្តពោធិ៍សាត់មានប្រជាជនសរុបប្រមាណ ៤៣៥០០១ នាក់ (ទិន្នន័យឆ្នាំ ២០១១ បានពីរបាយការណ៍សន្និបាតបូក សរុបការងារគ្រប់វិស័យប្រចាំឆ្នាំ២០១០ និងទិសដៅការងារឆ្នាំ២០១១នៃសាលាខេត្តពោធិ៍សាត់) រួមមានប្រុសចំនួន ២១២១៥១ នាក់ និងស្រីចំនួន ២២២៨៥០នាក់ ប្រភពទិន្នន័យបានពីខុទ្ទកាល័យខេត្តពោធិ៍សាត់ ដង់ស៊ីតេប្រជាជនមានប្រហែល ៣៣ នាក់/គ.ម² ។

ការសាងសង់អាងទី១នៃគំរោងវារីអគ្គិសនីស្ទឹងរ៉ាតៃនេះ បានធ្វើអោយប៉ះពាល់ផ្ទាល់ដល់ប្រជាពលរដ្ឋចំនួនបីភូមិ (ភូមិអូរសោម, ភូមិកណ្ដាល និងភូមិឆាយលូក) មានប្រជាពលរដ្ឋប៉ះពាល់សរុបចំនួន ៣៧គ្រួសារ ដែលមានមនុស្សសរុប១៨៥ នាក់ ក្នុងនោះមាន៤គ្រួសារនៅភូមិឆាយលូក ដែលត្រូវផ្លាស់ប្ដូរទីលំនៅទៅកាន់ទីទួលមានសុត្ថិភាពស្ថិតនៅក្នុងភូមិអូរសោម ដែលមានកំរិតនីវ៉ូលើសពី ៥២០ម ។ ចំពោះប្រជាជនដែលត្រូវប្ដូរលំនៅដ្ឋាននោះមាន ដើមឈើហូបផ្លែ និងដំណាំចំនួន១៩៥៤ ដើម/គុម្ព, ផ្ទះ០៤ខ្នង (មានផ្ទះ២ប្រភេទ), និងមានសំណង់ផ្សេងៗ ដូចជា ផ្ទះបាយ, ជង្រុកស្រូវត្រូវប៉ះពាល់ និងរុះរើចេញពីក្នុងអាងនេះផងដែរ ។ ទោះជាយ៉ាងនេះក៏ដោយក្រុមហ៊ុនមានផែនការណ៍ផ្ដល់សំណងច្បាស់លាស់ ។

ក្នុងការអភិវឌ្ឍន៍គំរោងវារីអគ្គិសនីស្ទឹងអាតៃនេះក៏បានធ្វើអោយបាត់បង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈមួយចំនួនដូចជា: ផ្លូវលំគ្រួសក្រហម (ស្ថានភាពមធ្យម) ប្រវែង៤.៦៥គម ពីប្រម៉ោយទៅឃុំអូរសោម, ដីបញ្ចុះសពនៅភូមិអូរសោមចំនួន ២.៤៥៥៨ ហ.ត, ព្រៃ ក្រវាញរបស់សហគមន៍នៅឃុំអូរសោម ចំនួន២៧.៦១ហ.ត ដែលលិចលង់ដោយសារបិទទឹកនៅអាងទី១នេះ ។

មុខរបរសំខាន់ៗរបស់មេគ្រួសារនៃប្រជាពលរដ្ឋដែលបានសម្ភាសន៍ នៅក្នុងតំបន់គំរោងមានចំនួន ៧៩% ជាកសិករ ១៥%, ជាមន្ត្រីរាជការ (ជំទប់ឃុំ, មេភូមិ, ទាហ៊ាន) ,៣% ជាអ្នកលក់ដូរ , និងបុគ្គ លិកក្រុមហ៊ុន ៣% ។ កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោងគឺប្រាក់ចំណូលមធ្យមម្នាក់ៗមាន ៦៤៧.៩៦ ដុល្លាអាមេរិក ទាបជាងប្រាក់ចំណូល ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជា គឺ ៨៣០ ដុល្លាអាមេរិក ឆ្នាំ ២០១១ ក្នុងម្នាក់ ក្នុងមួយឆ្នាំ។ តាមការសិក្សា និងធ្វើការសម្ភាន៍ជាមួយអាជ្ញាធរភូមិ ឃុំ និងប្រជាពលរដ្ឋនៅជុំវិញ និងក្នុងតំបន់គំរោងបានរកឃើញថា មានសាលាបឋមសិក្សា ០១កន្លែងមាន ០២ ខ្នង ដែលមាន ០៦ បន្ទប់ ចំនួនសិស្ស ១៤៨ នាក់ ក្នុងនោះស្រី ៥៦នាក់ និងគ្រូ ០៤ នាក់។ នៅក្នុងឃុំអូរសោមមិនមានអនុវិទ្យាល័យទេ ប្រសិនបើចង់បន្តការសិក្សានៅអនុវិទ្យាល័យវិទ្យាល័យពួកគេត្រូវទៅរៀននៅប្រម៉ោយ ។ ចំពោះកំរិតនៃការសិក្សារៀនសូត្ររបស់អ្នកភូមិមានកំរិតទាបនៅឡើយ ។ មេគ្រួសារដែលបានសម្ភាសន៍ចំនួន ៣៣គ្រួសារ

Draft

ក្នុងនោះមានមេគ្រួសារ ជាបុរសចំនួន ១៥ នាក់ និងស្ត្រីដែលជាមេគ្រួសារចំនួន ៧នាក់ដែលចេះអាន និងសរសេរអក្សរខ្មែរ (កំរិតវប្បធម៌ត្រឹមថ្នាក់ទី ៣ ដល់ ទី ៥) ។

យោងតាមការចុះសិក្សាដោយផ្ទាល់នៅតំបន់គំរោងគិតចាប់ពីអាងទី១នៅឃុំអូរសោម (មើលផែនទីទី៤) បានបង្ហាញឱ្យឃើញថា ដីដែលបានប្រើប្រាស់ដោយប្រជាពលរដ្ឋសរុបមានចំនួនប្រមាណ ៣៩.១ ហិកតា (ដីកសិកម្ម , ដីបុស្ស , ដីលំនៅដ្ឋាន, ដីកប់សាកសព) ដែលប៉ះពាល់ដោយសារគំរោង ចំណែកឯនៅក្នុងអាងទី២ និងកន្លែងសាងសង់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនីគឺមិនមាន ដីកាន់កាប់ដោយប្រជាពលរដ្ឋទេ។ ចំពោះដីដែលកាន់កាប់ដោយប្រជាជនទាំងនេះគឺ មានការអនុញ្ញាតិពីថ្នាក់ភូមិឬឃុំក៏ប៉ុន្តែប្រជាជនទាំងអស់នោះមិនមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលចេញដោយអគ្គនាយកសុរិយោដី និងភូមិសាស្ត្ររបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីនៅឡើយទេ។

យោងតាមការសម្ភាសន៍ផ្ទាល់របស់ក្រុមការងារ SAWAC អំពីការផ្គត់ផ្គង់ទឹក និងអនាម័យនៅក្នុងតំបន់គំរោងបានបង្ហាញថាប្រជាពលរដ្ឋនៅក្នុងតំបន់គំរោងពុំមានប្រព័ន្ធទឹកស្អាតសំរាប់ផ្គត់ផ្គង់ប្រើប្រាស់ទេ។ ប្រភពទឹកដែលប្រជាពលរដ្ឋទាំងបីភូមិយកមក ប្រើប្រាស់មានដូចតទៅ : ទឹកស្ទឹង អូរ ៣៩.៣៩% , បឹង,ស្រះ,ត្រពាំង ១៨.១៨ % អណ្តូងជីក និងអណ្តូងលូ ៧៥.៧៦% , ទឹកភ្លៀង ១០០% ។

យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងារ SAWAC បានរកឃើញថា សុខភាពរបស់ប្រជាពលរដ្ឋទាំង០៣ ភូមិភាគច្រើនអ្នកភូមិក្នុងតំបន់នេះ ច្រើនតែកើតមានជំងឺគ្រុនចាញ់ប្រមាណ ៦៦.៦៧% និងជំងឺកើតឡើងដោយសារទឹកដូចជា រាគ ៦៦.៦៧%, គ្រុនពោះវៀន ៦៣.៦៤%, សើស្បែក៣០.៣០%, គ្រុនឈាម ៩.០៥%, និងគ្រុនក្តៅសន្លាក់ ២៧.២៧%។ ក្នុងឆ្នាំ ២០១១ ប្រជាពលរដ្ឋក្នុងតំបន់គំរោងភាគច្រើនកើតជំងឺគ្រុនចាញ់ គឺកើនឡើង ១៤ %, ជំងឺគ្រុនឈាមកើនឡើង៣.៥% ។ ចំពោះជំងឺផ្សេងទៀត គឺមានតួលេខប្រហាក់ប្រហែលគ្នាខុសគ្នាតិចតួច (ប្រៀបធៀបទិន្នន័យ ឆ្នាំ ២០០៨ និង២០១១) ។ ក្នុងករណីពួកគាត់មានជំងឺធ្ងន់ធ្ងរ ត្រូវបញ្ជូនទៅព្យាបាលនៅ មន្ទីរពេទ្យបង្អែក ខេត្តពោធិ៍សាត់ចំងាយមធ្យមប្រមាណ១៦០គ.ម. ពីភូមិ រឺក៏ទៅព្យាបាលនៅពេទ្យបង្អែក ខេត្តកោះកុងក៏បាន ចំងាយប្រមាណ១០៣គ.ម ពីអូរសោមដែលមានផ្លូវល្អជាងទៅពោធិ៍សាត់ (ពិបាកខ្លាំងចំងាយ២គ.មមុំស្ទឹងឆាយលូក ឃុំអូរសោម) ។

យោងតាមការសិក្សាបានបង្ហាញអោយឃើញថានៅក្នុងតំបន់គំរោង និងតំបន់ក្បែរខាងនៃវារីអគ្គិសនីស្ទឹងអាតៃ ដែលស្ថិតនៅក្នុងឃុំអូរសោមនេះ មានតំបន់ទេសចរណ៍ធម្មជាតិបីកន្លែងសំខាន់ៗដូចជា តំបន់ព្រៃការពារក្រវាញរបស់ឃុំអូរសោម, តំបន់វាលវែងមានវាលស្មៅធំល្វឹងល្វើយ និងមានទេសភាពល្អត្រកាល, និងជំរកសត្វក្រពើភ្នំស្ថិតនៅក្នុងទឹកដីភូមិសាស្ត្រភូមិគៀនជង្រុក និងតំបន់ទឹកធ្លាក់ឆាយប្រុយ ដែលជាតំបន់មានសក្តានុពលសំរាប់ទេសចរណ៍ ឬអេកូទេសចរណ៍ទៅថ្ងៃអនាគត ។

## ៦. ការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជននៅក្នុងតំបន់គំរោង

ការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជនដែលពាក់ព័ន្ធដោយសារគំរោងនេះ គឺជាចំណុចមួយដ៏សំខាន់ដែលធ្វើឡើងដើម្បីឱ្យសាធារណជនដែលពាក់ព័ន្ធទាំងនេះផ្តល់នូវមតិយោបល់ និងសំណូមពរក្នុងការជួយដល់ការអនុវត្តគំរោងឱ្យបានល្អប្រសើរ និងមានភាពរលូន ។

### ក) គោលបំណងនៃការប្រឹក្សា

- គោលបំណង នៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជនមានគោលបំណងដូចតទៅ :

Draft

- ស្វែងរកមតិរិះគន់សំណូមពរ បញ្ហាទំនាស់ និងរកវិធីសាស្ត្រកែលំអផ្សេងៗ ដើម្បីឱ្យគំរោងនេះទទួលបាន ជោគជ័យ ។
- រកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាននៃគំរោងវារីអគ្គិសនីកំចាយនេះឱ្យកាន់តែមានប្រសិទ្ធភាព ។

**៩) លទ្ធផល នៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជន**

ក្រុមការងារសិក្សាស្រាវជ្រាវផ្នែកការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមរបស់ SAWAC បានធ្វើការប្រឹក្សា និង ពិគ្រោះយោបល់ ពីអាជ្ញាធរពាក់ព័ន្ធ និងអង្គភាពពាក់ព័ន្ធ ដូចខាងក្រោម:

- អភិបាល ខេត្តពោធិ៍សាត់
- អង្គការ CI និង FFI
- អភិបាលស្រុកវាលវែង ស្រុកភ្នំក្រវាញ និងស្រុកសំពៅមាស
- អនុប្រធានមន្ទីរបរិស្ថាន ខេត្តពោធិ៍សាត់
- មេឃុំពាក់ព័ន្ធជាមួយគំរោង
- មេភូមិពាក់ព័ន្ធជាមួយគំរោង
- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តពោធិ៍សាត់
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់
- ប្រធានមន្ទីរធនធានទឹក និង ឧតុនិយមខេត្តពោធិ៍សាត់
- ប្រធានមន្ទីរកសិកម្ម ខេត្តពោធិ៍សាត់
- និងប្រជាពលរដ្ឋ ដែលត្រូវប៉ះពាល់ជាមួយគំរោង ។

<u>***សំគាល់:***</u> កំណត់ហេតុអំពីកិច្ចពិគ្រោះយោបល់នេះមានរាយរាប់លំអិតនៅជំពូកទី៦ នៃរបាយការណ៍នេះ ។

## ៧. ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដោយសារសកម្មភាពគំរោង

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA) នេះគឺជាការអង្កេត សិក្សាស្រាវជ្រាវលំអិតបន្ថែម និងការប្រជុំពិភាក្សាជាមួយសហគមន៍ / ប្រជាជនមូលដ្ឋាន អង្គការនានា និងស្ថាប័នជាប់ទាក់ទងនឹងគំរោងគ្រប់ជាន់ថ្នាក់ លើទីតាំងគំរោង សមាសភាពគំរោង ការងារសាងសង់គំរោង និងកិច្ចដំណើរការរបស់វា ដើម្បីស្វែង និងលទ្ធផលប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសេដ្ឋកិច្ច-សង្គមក្នុងដំណាក់កាលរចនាគំរោង (Project Design) **សាងសង់** (Project Construction) ប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគំរោង (Project Closure) ។ ហេតុប៉ះពាល់បរិស្ថានទាំងនោះត្រូវរកវិធានការកាត់បន្ថយ និងធ្វើផែនការគ្រប់គ្រងបរិស្ថាន នៃដំណាក់កាលរបស់គំរោងទាំងនោះ ដោយមានការអនុវត្តន៍ពីម្ចាស់គំរោងរួមកិច្ចសហការត្រួតពិនិត្យវាយតំលៃ តាមរយៈប្រជុំពិគ្រោះយោបល់ផ្ទាល់ និងតាមរយៈសិក្ខាសាលាដែលបានចូលរួមពីបណ្តាស្ថាប័នជំនាញពាក់ព័ន្ធ ដូចជាសាលាខេត្តពោធិ៍សាត់, មន្ទីរបរិស្ថាន ខេត្តពោធិ៍សាត់, មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់, មន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តពោធិ៍សាត់, មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ .មន្ទីរកសិកម្មខេត្តពោធិ៍សាត់, ខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តពោធិ៍សាត់, ខ័ណ្ឌរដ្ឋបាលជលផល ខេត្ត ពោធិ៍សាត់, អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់, ដោយមានការគ្រប់គ្រងតាមខ្សែបណ្តោយពីក្រសួងបរិស្ថាន, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងធនធានទឹក និងឧតុនិយម . ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការក្រៅរដ្ឋាភិបាល ផ្សេងៗ ដូចជា អង្គការ CI, Wildlife Alliance, និងអង្គការទន្លេអន្តរជាតិ ។ ក្នុងដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះ ក្រុមការងារ SAWAC បានប្រើប្រាស់តារាង Checklist សំរាប់គំរោងវារីអគ្គិសនី (គោលការណ៍ណែនាំ វ.ហ.ប របស់ធនាគារអភិវឌ្ឍន៍អាស៊ី) ដើម្បីជំនួយក្នុងការសិក្សា និងវាយតំលៃតាមផ្នែកសំខាន់ៗទៀតផង ។

Draft

បន្ថែមពីលើនេះទៀតតារាង Checklist របស់ក្រសួងបរិស្ថានក៏បានកំណត់ផងដែរ នូវទំហំផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថានរូបសាស្ត្រ និងសេដ្ឋកិច្ច-សង្គម រួចជ្រើសយកការវាយតំលៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណាដែលមានកំរិតតិច មធ្យម និង ខ្លាំង មកធ្វើវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនេះឱ្យដល់កំរិតអប្បបរមា ។

យោងតាមឯកសាររចនាប្លង់គំរោង និងទីតាំងភូមិសាស្ត្រតំបន់នេះឃើញថាៈ ទីតាំងគំរោងនឹងមានការប៉ះពាល់ដល់តំបន់អភិរក្សព្រៃឈើភ្នំក្រវាញ និងដែនជំរកសត្វព្រៃភ្នំសំកុសហើយផលប៉ះពាល់អវិជ្ជមានដែលនឹងកកើតចេញពីសកម្មភាពគំរោងតាមដំណាក់កាលនិមួយៗតំបន់ព្រៃការពារដងទង់មានពណ៌នាតាមលំដាប់លំដោយខាងក្រោមនេះ:

Draft

**ក) ហេតុប៉ះពាល់អវិជ្ជមាន**

**ក-១) ដំណាក់កាលរចនាគំរោង**

ក្នុងដំណាក់កាលនេះគំរោងពុំមានសកម្មភាព ដែលបង្កឱ្យមានផលប៉ះពាល់ធំដុំឡើយ ។ ដំណាក់កាលរចនាគំរោងគឺ មាន. អ្នកជំនាញការតាមផ្នែកបច្ចេកទេស ធ្វើការសិក្សាស្រាវជ្រាវទៅតាមជំនាញបច្ចេកទេសរៀងៗខ្លួនដើម្បីរចនាប្លង់គំរោងតាមសមាសភាពនីមួយៗ ។ ការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗដល់ធនធានបរិស្ថាន និងសង្គម រួមមានដូចតទៅ :

**ក.១.១ ធនធានរូបសាស្ត្រ**

- ប៉ះពាល់តិចតួចដល់ជីវចំរុះក្នុងស្ទឹងអាតៃនៅផ្នែកខាងក្រោមកន្លែងសាងសង់ទំនប់ទី២ ។
- អាចមានផលប៉ះពាល់ខ្លះៗដល់គុណភាពដី បណ្តាលមកពីការហៀរ ឬប្រេង និងការបោះកាកសំណល់ផ្សេងៗ ដោយបុគ្គលិក-កម្មកររបស់គំរោងក្នុងពេលសិក្សា។
- នៅខណៈនៃការសិក្សានេះដែរប្រភពទឹកនៃស្ទឹងអាតៃអាចមានផលប៉ះពាល់តិចតួច ដោយសារការបង្ហូរសំណល់រឹង-រាវចេញពីផ្ទះបាយ និងការបន្ទោរបង់របស់បុគ្គលិក-កម្មករគំរោង ។
- អាចមានការប៉ះពាល់តិចតួច ការខួងដី សម្រាប់សិក្សាអំពីគ្រឹះទំនប់ដែលមានម៉ាស៊ីនខួង ៣គ្រឿង, ការដឹកជញ្ជូនក្រុមអ្នកសិក្សា និងសម្ភារ ដោយរថយន្ត ២គ្រឿង និងសំលេងអ៊ូរអរនៃអ្នកសិក្សាទាំងនោះ ។
- ទោះជាយ៉ាងនេះក្តី ក្នុងដំណាក់កាលនេះ បើគំរោងគ្រោងខុសធ្វើឱ្យមានការខ្វះ ទឹកនៅតំបន់អន្លង់ល្អាងខាងក្រោមទំនប់ទី២ដែលមានក្រពើភ្នំរស់នៅ ។ ក្រុមហ៊ុនបានគ្រោងបញ្ចេញទឹកមកតំបន់នេះ១.៥ម៣.វិនាទីឥតដាច់ទាំងរដូវប្រាំង និងរដូវវស្សា ។

**ក.១.២ ធនធានជីវសាស្ត្រ**

- ធ្វើឱ្យប៉ះពាល់ដល់ប្រភេទព្រៃឈើ និងសត្វព្រៃនៃតំបន់អភិរក្សទាំបីនេះតិចតួច គឺដោយសារសកម្មភាពសិក្សាគំរោងមានសំឡេងពីគ្រឿងចក្រ ភាពខ្សៀវខ្សារ ការទន្រ្ទានចូលក្នុងព្រៃពីក្រុមបុគលិក-កម្មករខ្លះ ក្រោយពីការងារដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ ឬការជួញដូរសត្វព្រៃសំរាប់ធ្វើម្ហូប និងកាប់ឈើលក់ឱ្យឈ្មួញជាដើម ។
- អាចប៉ះពាល់ដល់ធនធានព្រៃឈើខ្លះដែរ ដោយសារការកាប់កូនឈើធ្វើស្ពាន និងរានព្រៃធ្វើផ្លូវ ។
- ក្នុងដំណាក់កាលរចនាគំរោងនេះ អាចប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃខ្លះដែរ ដោយសារសកម្មភាពសិក្សាគំរោង ។
- គំរោងសាងសង់ទំនប់វារីអគ្គិសនីនេះ ពុំមានរចនាប្លង់គំរោងសំរាប់ឱ្យត្រីឆ្លងកាត់នោះទេ ដែលជាហេតុធ្វើឱ្យមានបញ្ហាប៉ះពាល់ដល់ចរាចរត្រី នៅពេលដែលគំរោងទាំងមូលសាងសង់ និងដំណើរការ ។

ក.១.៣ ធនធានសេដ្ឋកិច្ច-សង្គម

- អាចនឹងប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ ដោយសារខ្លាចបាត់បង់ដីស្រែចំការ និងលំនៅដ្ឋានដោយសារការបាក់ទំនប់ ។
- អាចនឹងមានជនឆ្លៀតឱកាសដើរបំផុសប្រជាពលរដ្ឋ ក្នុងគោលបំណងចង់ទាមទារផលប្រយោជន៍មិនសមហេតុផល ដើម្បីធ្វើការទាមទារសំណងពីក្រុមហ៊ុន ។
- បង្កឱ្យមានការប៉ះពាល់ជាមធ្យមដល់សុខមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ដោយសារតំបន់នេះជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្និ ។ល ។
- អាចនឹងមានគ្រោះថ្នាក់ ដោយសារតំបន់នោះមិនដែលស្គាល់ភូមិសាស្ត្រ ដូចជាមាន គ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បង្កប់ក្នុងដីដូចជា តំបន់អូរសោមនេះជាដើម ។ ក្រុមហ៊ុនបានសហការណ៍ជាមួយកងយុទ្ធពលខេមរភូមិន្ទធ្វើការបោសសំអាតយុទ្ធភណ្ឌ និងគ្រាប់មីនមិនទាន់ផ្ទុះរួចរាល់ហើយ ។

**ក-២) ដំណាក់កាលសាងសង់គំរោង**

នៅក្នុងដំណាក់កាលនេះមានការប៉ះពាល់អវិជ្ជមានសំខាន់ៗ មួយចំនួនមានដូចតទៅ :

ក.២.១ ធនធានរូបសាស្ត្រ

- អាចនឹងបណ្តាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងគំរោង ដោយសារសកម្មភាពការឈូសឆាយ និងពង្រាបដីស្រទាប់លើដែលមានគំរបព្រៃ ដើម្បីធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ។
- ប៉ះពាល់ខ្លាំងដល់បរិមាណធារទឹករបស់ស្ទឹងអាតៃផ្នែកខាងលើ ដោយសារការទប់ទំនប់កាត់ស្ទឹងអាតៃដើម្បីធ្វើទំនប់ទី១ .ទំនប់ទី២ និងសំណង់ពាក់ព័ន្ធផ្សេងៗទៀត ។
- ដំណាក់កាលសាងសង់នេះ មានការហូរច្រោះដីខ្លាំងជាពិសេស ក្នុងតំបន់២ ដោយសារការឈូសឆាយដីគំរបព្រៃឈើ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង ។
- មានការរញ្ជួយ ដែលបង្កឡើងដោយសារការបំផ្ទុះផ្ទាំងថ្មនៅការដ្ឋានធ្វើទំនប់ទាំងពីរ និងកន្លែងយកថ្មចំណុចឆាយប្រុយ ដែលធ្វើឱ្យប៉ះពាល់(ដោយមានការរំខាន) ដល់ប្រជាពលរដ្ឋ និងគ្រួសារកម្មករដែលរស់នៅជុំវិញតំបន់ទាំងនោះទៀតផង ។
- មានការបំពុលគុណភាពទឹកស្ទឹងអាតៃខ្លាំង ដោយសារការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង បណ្តាលមកពីការខួង ឬការងារដី ការងារបេតុង ការងារបំផ្ទុះ និងកិនថ្មភ្នំ និងការហូរច្រោះពីតំបន់កំពុងសាងសង់សំណង់ផ្សេងៗរបស់គំរោង ។
- អាចនឹងបំពុលខ្យល់ដោយសារការដុតព្រៃឈើដើម្បីសំអាតការដ្ឋាន និងផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសំភារៈ និងការបំផ្ទុះសម្រាប់ការងារសាងសង់របស់គំរោង ។
- មានការបំពុលដីមានកំរិតធ្ងន់ធ្ងរ ដោយសារការកំពប់នៃប្រេងឥន្ធនៈ ការកំពប់នៃសារធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដី ដូចជាកាកសំណល់ចេញពី ឬលេចធ្លាយពីគ្រឿងចក្រ និងរថយន្តគ្រប់ប្រភេទដែលដំណើរការសាងសង់គំរោងនេះព្រមទាំងកាកសំណល់ចេញពីផ្ទះបាយគ្រប់ប្រភេទ ។
- នេះមានការរំខានដោយលំលេង និងរំញ័រខ្លាំង ដោយសារសំលេងចេញពីគ្រឿងចក្រ ការបំផ្ទុះថ្ម និងការខួងគ្រឹះទំនប់ ដែលកើតឡើងនៅការដ្ឋានកិនថ្ម និងការដ្ឋានសាងសង់ទំនប់ ។

Draft

### ក.២.២ ធនធានជីវសាស្ត្រ

- បានបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការធ្វើចរាចររបស់មច្ឆជាតិ និងជីវសាស្ត្រដទៃទៀត ដែលរស់នៅក្នុងទឹក ដោយសារក្រុមហ៊ុនទប់ទំនប់បណ្តោះអាសន្នកាត់ស្ទឹងអារ៉ែង ដើម្បីសាងសង់ទំនប់វារីអគ្គិសនីនេះ ។
- តំបន់គំរោងមានផ្ទៃដីសរុប ៥.០៩៨.៦៨ហ.ត ដែលចែកជាបីតំបន់គឺ តំបន់១ជាតំបន់ផ្ទៃអាងទាំងពីមានចំនួន ៤.២៣៧ ហ.ត. តំបន់២ជាតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោងមានចំនួន៨.១៣.២៣ ហ.ត និងតំបន់៣ជាតំបន់តាមគន្លងខ្សែបញ្ជូនចរន្ត តង់ស្យុងខ្ពស់១១៥មានចំនួន ៤៨.៤៤ហ.ត។ ដីប៉ះពាល់មាន ៤៦១១.៣២ហ.ត ក្នុងនោះដីព្រៃឈើមាន ៤១៨៧.៨១ហ.ត និងដីប្រជាជន ( មានផ្លូវថ្នល់ វាលស្មៅ និងដីទន្លេ) មាន ៤២៣៥.១ហ.ត ។
- កាប់ឆ្ការគំរបព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសំភារៈសាងសង់ បង្កនាំឱ្យមានការភ័យខ្លាចដល់សត្វព្រៃទាំងនោះ ដោយសារមានសំលេងរំខានខ្លាំងៗ ចេញពីម៉ាស៊ីន គ្រឿងយន្តគ្រឿងផ្ទុះ និងសំឡេងរបស់បុគ្គលិក-កម្មករគំរោង។

### ក.២.៣ ធនធានសេដ្ឋកិច្ច-សង្គម

- មានការប៉ះពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ប្រជាពលរដ្ឋ ក្នុងអាងទី១ មានដីស្រែទូលចំនួន ១២.២៦៥ម$^{២}$ ដីចំការ ១៧៦.៧០៩ម$^{២}$. ដីបុស្ស ១៤៦.៩៥៦ម$^{២}$ និងដីលំនៅដ្ឋាន ៥០០០ម$^{២}$ ដែលកាន់កាប់ ដោយ៣៧គ្រួសារខាងលើនេះ ហើយក៏មានដីបញ្ចុះសពភូមិអូរសាម ២៤.៥៥៨ ម$^{២}$ និងដីសហគមន៍ព្រៃការពារក្រវាញ ឃុំអូរសោម ២៧.៦១.០០ ម$^{២}$ ដោយសារការបង្កើត អាងទី១នេះ ។
- មានការប៉ះពាល់ខ្លាំងដល់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយសារការប៉ះពាល់ដីកសិកម្មលើសពី ១០% ពីការបិទទឹកបំពេញអាងចំពោះ១៣គ្រួសារក្នុងនោះ០៤គ្រួសារ នឹងត្រូវជំលៀសទៅនៅទីកន្លែងតាំងលំនៅថ្មី និងប៉ះពាល់ដល់ព្រៃសហគមន៍ការពារក្រវាញឃុំអូរសោមដែលជាប្រភពចំណូលបន្ថែមសំរាប់គ្រួសារនិមួយៗក្នុងសហគមន៍នេះ។
- ប៉ះពាល់ដល់កន្លែងសក្ការៈបូជា ដីកប់ខ្មោចរបស់ភូមិអូរសោមចំនួន២៤.៥៥៨ ម$^{២}$ ដោយសារការបង្កើតអាងទី១នេះ
- តាមការសិក្សានៃការប្រើប្រាស់ដីនៅចំណុចស្ទឹងតាចាន់ ភូមិឆាយល្វេក តំបន់អនុស្ភានីយអូរសោមមានការកើតឡើង ១១០ហ.ត។
- មានការប៉ះពាល់ខ្លាំងដល់គុណទឹកក្នុងការប្រើប្រាស់ទឹកស្ទឹង ដោយសារសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង និងការគ្រប់គ្រងកាកសំណល់រឹង-រាវមិនបានល្អធ្វើឱ្យបំពុលដល់ប្រភពទឹកលើដី និងក្រោមដីដែលជាប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹកប្រជាពលរដ្ឋក្នុងតំបន់។
- បង្កប៉ះពាល់ជាមធ្យមដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ក្នុងតំបន់ ដោយសារសកម្មភាពសាងសង់គំរោង និងការដឹកញ្ជូនសម្ភារ បរិក្ខាគ្រឿងចក្រចូលទៅទីតាំងគំរោង ដូចជាការស្រុតឬ ខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវដែលមានចំណោទ ឡើងទួល និងផ្លូវកោង ។ល។
- មានការប៉ះពាល់ខ្លាំងដល់សុខមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន និងប្រជាពលរដ្ឋក្នុងតំបន់ ដោយសារធូលីដី ធូលីស៊ីម៉ងត៍ ការខ្ចាតថ្ម បណ្តាលមកពីសកម្មភាពដាក់បន្ទុះ និងចំហាយចេញពីការប្រើប្រាស់សារធាតុគីមីដែលលាយជាមួយបេតុងជាដើម ។

Draft

- មានការប៉ះពាល់ខ្លាំង និងបាត់បង់ទឹកធ្លាក់ឆាយ ប្រុយមានកំពស់ដល់ទៅ៥៥ម៉ែត្រដែលជាតំបន់អាចបង្កើតជាតំបន់ទេសចរណ៍ធម្មជាតិដ៏ល្អ ដោយសារក្រុមហ៊ុនបានយកថ្មសំរាប់សាងសង់តំរោងនៅតំបន់នេះ ។
- អាចនឹងមានហានិភ័យ ដោយសារគ្រោះធម្មជាតិ ការកើតមានការរញ្ជួយដី បន្ទុះភ្នំភ្លើង ។

ប្រជាពលរដ្ឋដែលរងការប៉ះពាល់ក្រោយការសាងសង់តំរោងមាន៣៧គ្រួសារ ក្រុមហ៊ុនបានរៀបចំផែនការតាំងទីលំនៅឡើងវិញរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារតំរោង រួមទាំងមានសំណងដែលមានតំលៃសរុប ១២៥.១៨១ដុល្លារអាមេរិក។ ចំពោះប្រជាជន៤គ្រួសារក្រុមហ៊ុនតំរោងសង់ផ្ទះឈើដំបូលប្រក់ស័ង្កសី ទំហំ(៥ម x ៧ ម) និងផ្តល់ដីលំនៅដ្ឋានក្នុងមួយ គ្រួសារចំនួន៥០ម x ៥០ម ទៀតផង ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ៤០ដុល្លាអាមេរិក សំរាប់ការដឹកជញ្ជូនសម្ភារទៅនៅតំបន់តាំងទីលំនៅថ្មី។ បន្ថែមពីលើប្រាក់ឧបត្ថម្ភនេះ ចំពោះមេគ្រួសារណាដែលស្ថិតក្នុងករណីជនងាយរងគ្រោះ (ចាស់ជរា ស្ត្រីមេម៉ាយ ជនពិការអសមត្ថភាពពលកម្ម) ឧបត្ថម្ភក្នុង ១គ្រួសារបានតែម្តងទេគឺ ១៥០ ដុល្លាអាមេរិក ដល់ ៦គ្រួសារដែលបានចុះបញ្ជីប៉ះពាល់ដោយសារតំរោង។ ជាងនេះទៅទៀតចំពោះ១៣គ្រួសារដែលបាត់បង់ដីផលិកម្ម(ស្រែ និងចំការ)ចាប់ពី១០%ឡើងទៅមានការឧបត្ថម្ភ៤១៣ដុល្លារអាមេរិកសំរាប់ការស្តារចំណូលក្នុងអន្តរពេល១ឆ្នាំ។

**ក-៣) ដំណាក់កាលប្រតិបត្តិ និងថែទាំតំរោង**

សកម្មភាពតំរោងក្នុងដំណាក់កាលនេះ នឹងអាចបង្កឱ្យមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដូចតទៅ:

**ក.៣.១ ធនធានរូបសាស្ត្រ**

- កាលនេះបង្កឱ្យមានផលប៉ះពាល់ខ្លាំង ដល់ប្រព័ន្ធជលសាស្ត្រ នៃស្ទឹងអាតៃ និងខ្សែទឹកខាងក្រោម ដោយសារ ការបង្ខាំងទឹកដើម្បីស្តុកទុកឱ្យបានដល់កំពស់គ្រប់គ្រាន់សំរាប់អូសទួប៊ីនភ្លើងកំលាំងសរុប ១២០មេហ្គាវ៉ាត់ និងការបញ្ចេញទឹកពី ទំនប់ទី២ របស់តំរោងមិនគ្រប់គ្រាន់ធ្វើឱ្យប៉ះពាល់ដល់របបទឹករបស់ស្ទឹងអាតៃ ដែលស្ថិតនៅចន្លោះទំនប់នោះ និងអគារថាមពល ទី២ (ចំងាយប្រមាណ ៧ គ.ម )ដែលជាតំបន់អន្លង់ល្អាងមានក្រពើភ្នំរស់នៅ ។

**ក.៣.២ ធនធានជីវសាស្ត្រ**

- ការបិទទ្វារទឹកដើម្បីតំកល់ ទឹកក្នុង អាងទាំងពីរធ្វើឱ្យខ្វះទឹកមកតំបន់ក្រោមទំនប់ទី២ ដែលជាកន្លែងដែល ក្រពើភ្នំកន្លាយ រស់នៅ ដោយសារពួកវាមិនមានអាហារ និងទឹកគ្រប់គ្រាន់។
- មានការប៉ះពាល់ខ្លាំង ដល់ព្រៃឈើ និងជីវកសត្វព្រៃ ដោយសារសកម្មភាពរបស់ បុគ្គលិក -កម្មករ និងអ្នកមកពីខាងក្រៅទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ឬដាក់អន្ទាក់សត្វ និងជួញដូរ ចរាចរឈើ និងសត្វព្រៃ ធ្វើឱ្យឈើកម្រ (ចាន់ស ឈើខ្មៅ គ្រើល ធ្នង់ អង្កត់ខ្មៅ ម្រះព្រៅភ្នំ តាត្រាវ និង ក្រញូង ) និងសត្វព្រៃ មាន ដំរី ខ្លាធំ ពង្រូល កែះក្តាន់ ខ្លាឃ្មុំ ខ្លាលឿងមាស អណ្តើកមាស អណ្តើកក្របីក្បាលលឿង ដោយសត្វទាំងនោះថយចុះឈានទៅរកការបាត់បង់ផុតពូជទៀតផង ។

**ក.៣.៣ ធនធានសេដ្ឋកិច្ច-សង្គម**

- អាចនឹងប៉ះពាល់តិចតួចដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ដូចជាពួកគាត់មានជំនឿលើអារក្ស អ្នកតាព្រៃភ្នំដោយបង្កើតជាព្រៃអ្នកតា គោរពក្រពើភ្នំជាដើម ដោយសារក្រុមហ៊ុននាំយក បុគ្គលិក-កម្មករតំរោងមកពីតំបន់ផ្សេងទៀត ឬជនបរទេស ។
- បង្កឱ្យមានការប៉ះពាល់ជាមធ្យមដល់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនៅ តំបន់ផ្នែកខាងក្រោម ដោយសារទឹកក្នុងអាងស្តុកមានគុណភាពមិនល្អ ដោយសារការរលួយនៃដំណាំពោត ដំឡូងមី ដែលបានដាំនៅក្នុងអាង និងមានក្លិនស្អុយមកពីការខ្វះអុកស៊ីសែនរបស់ទឹក។

- បង្កឱ្យប៉ះពាល់ជាមធ្យម ដល់ការប្រើប្រាស់ផ្លូវគមនាគមន៍របស់ប្រជាពលរដ្ឋក្នុងតំបន់ ដូចជា ការបិទផ្លូវមិនឱ្យប្រជាពលរដ្ឋចេញចូលតំបន់ដែលធ្លាប់បានប្រើប្រាស់ផ្លូវដែលខ្លួនបានស្ថាបនា ២៣គ.ម **និងសង់**ផ្លូវថ្មី៥៧គ.មនោះ ។
- គំរោងវារីអគ្គិសនីអាចកើតមានរុក្ខជាតិទឹកដូចជាចក កំប្លោក សារាយ ពើក និងសត្វល្អិតចង្រៃ ដូចជាមូស បាក់តេរី ឬសត្វល្អិតដែលអាចនឹងបង្កជំងឺ និងចម្លងជំងឺទៅសត្វ និងមនុស្សបាន ជាពិសេសជំងឺ**កើត**ឡើងពីទឹក និងសត្វល្អិតអាស្រ័យនឹងទឹក (Waterborn & water base diseases) ។
- អាចមានហានិភ័យដោយសារគ្រោះធម្មជាតិ ការធ្វេសប្រហែសផ្នែកសន្តិសុខ និងអំពើភាវរកម្ម ឬសង្គ្រាម ។

**ក-៤) ដំណាក់កាលបិទគំរោង**

ក្នុងដំណាក់កាលបិទគំរោងនឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោយពេលដំណើរការបាន ៣០ឆ្នាំមក ហើយចំពោះការផ្ទេរហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីនេះមានចែងលំអិតនៅក្នុងកិច្ចសន្យា។ រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគំរោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាសម្រេច ខ្លួនឯងហើយសង្ឃឹមថាក្នុងដំណាក់កាលបិទគំរោង របស់ក្រុមហ៊ុនចិននេះពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ ដែលគួរឱ្យកត់សម្គាល់ឡើយ ។

**ខ) ហេតុប៉ះពាល់វិជ្ជមាន**

- ការទប់ទំនប់ពីរកន្លែងកាត់ស្ទឹងអាតៃរបស់គំរោងវារីអគ្គិសនីស្ទឹងអាតៃ ខេត្តពោធិ៍សាត់**នេះ** អាចជួយបន្ថយជំនន់ធំៗ ដោយសារ ព្យុះភ្លៀងទីហ្វុងក្នុងតំបន់ភ្នំក្រវាញនេះបានមួយផ្នែកស្ទើរតែជារៀងរាល់**ឆ្នាំ**នៅតំបន់ស្ទឹងឫស្សីជ្រុំ និងតំបន់ស្ទឹងកោះប៉ោ និងព្រែកកោះប៉ោ ដែលតែងតែទទួលនូវទឹកជំនន់នៃស្ទឹងអាតៃ-ស្ទឹង**ឫស្សី**ជ្រុំនេះ ។
- ការប្រមែងបញ្ចេញទឹកពីទំនប់ទំនប់ទី២ មកខាងក្រោម ១.៥ម$^{៣}$/វិនាទី នៅរដូវ**ប្រាំងធ្វើ**ឱ្យកំហោត់ស្ទឹងអាតៃពីទំនប់ទី២ មកដល់គារផាមពលទី២មានទឹកគ្រប់គ្រាន់សំរាប់រក្សាជីវៈចំរុះក្នុងកំណាត់នៃស្ទឹង**នេះ** ។
- បរិមាណដ៏ធំធេងនៃអាងទឹកនេះ និងជំរៅទឹករបស់វាមិនសូវជ្រៅ (មធ្យមពី៨ម-២០ម) ដូចវារីអគ្គិសនីដទៃ អាចបង្កលក្ខខ័ណ្ឌ សមស្របសំរាប់ការអភិរក្ស និងការកើនឡើងនៃប្រភេទត្រី និងវារីសត្វមួយចំនួនធំក្នុងតំបន់ស្ទឹងអាតៃនេះ ។
- គំរោងវារីអគ្គិសនីស្ទឹងអាតៃនេះ អាចផលិតកំលាំងថាមពលបានប្រមាណ ១២០ មេហ្គាវ៉ាត់ (MW) ហើយការផ្តល់ថាមពលក្នុង១ឆ្នាំអាចស្មើនឹង ៥០៦.៩៤ ជីហ្គាវ៉ាត់ម៉ោង (GWh) គឺប្រមាណជា ៦៧.៣៣% **នៃ**ថាមពលអគ្គិសនីដែលប្រទេសកម្ពុជាផលិត បានសរុបនៅឆ្នាំ២០០៥ (៧៥៣ លានគីឡូវ៉ាត់ម៉ោង (KWh) រាប់បញ្ចូលទាំងថាមពលនាំចូលពីប្រទេសជិតខាង គឺប្រទេសថៃ និងវៀតណាម ។
- គំរោងវារីអគ្គិសនីនេះនឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនីដល់អ្នកប្រើប្រាស់តាមរោងចក្រ ឧស្សាហកម្មនានា លំនៅដ្ឋាន ទីសាធារណៈ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជាដើម្បីរំដោះភាពក្រីក្ររបស់ប្រជាជនក្នុងតំបន់គំរោង និងទូទាំងប្រទេស ព្រមទាំងធ្វើឱ្យសង្គមជាតិរីកចំរើនលើគ្រប់វិស័យ ។
- គំរោងនេះបានស្តារនិងសាងសង់ថ្មីហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះដូចជាកែលំអរផ្លូវចេញចូលពីទីរួមស្រុកវាលវែងទៅឃុំអូរបានប្រមាណជាង៣០គ.មឱ្យមានលក្ខណៈល្អប្រសើរដែលពីមុនពិបាកធ្វើ**ដំណើរ**ត្រូវចំណាយពេលអស់៣ទៅ៤ម៉ោងខាតទាំងថវិកា(តំលៃជួលម៉ូតូឌុបពីប្រមោយទៅអូរសោមក្នុងម្នាក់៥ទៅ៧ម៉ឺនរៀល) បច្ចុប្បន្នតំលៃតាក់ស៊ីអូរសោម-ពោធិ៍សាត់ តែ៣ម៉ឺនរៀលប៉ុណ្ណោះ ។
- ស្តារផ្លូវចូលពីកោះកុង ២៣គ.ម និងផ្លូវថ្មបាន៥៧គ.ម ។

Draft

- ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍គំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វាអាចនឹងធ្វើឱ្យដីក្នុងតំបន់កើនតំលៃខ្ពស់ជាងបច្ចុប្បន្ននេះ (២០១១)ជាពិសេសការប្រើប្រាស់ដីសំរាប់វិស័យឧស្សាហកម្ម កសិកម្មទំនើប និងទេសចរណ៍-អេកូទេសចរណ៍ ឬទេសចរណ៍-បរិស្ថាន ។
- គំរោងនឹងផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ៥០០នាក់ ក្នុងពេលសាងសង់គំរោង ជ្រើសរើសបុគ្គលិក-កម្មករជាមធ្យមចំនួនប្រហែលជា ៩០០នាក់ ។
- គំរោងវារីអគ្គិសនីស្ទឹងអាតៃនឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនីដល់ការអភិវឌ្ឍន៍លើគ្រប់វិស័យ រាប់តាំងពីការប្រើប្រាស់សំរាប់បំភ្លឺតាមលំនៅដ្ឋានទីក្រុង ការបំរើឱ្យវិស័យកសិកម្ម វិស័យទេសចរណ៍ ជាពិសេសវិស័យសិប្បកម្ម និងឧស្សាហកម្ម ដែលជាគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។
- គំរោងមានការបង់ផ្ទាល់ចូលចំណូលថវិកាជាតិ ដោយសារក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករលើការនាំចូល ប្រេងឥន្ធនៈសំរាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុកពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេលប្រតិបត្តិ និងថែទាំគំរោងទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា ។
- ទោះបីជាវារីអគ្គិសនីនេះប៉ះពាល់ដល់ព្រៃឈើ សត្វព្រៃ មច្ឆជាតិ និងប្រជាជនមួយចំនួនក៏ដោយ ប៉ុន្តែក្រុមហ៊ុនគ្រោងនឹងផ្តល់មូលនិធិសំរាប់ការពារបរិស្ថានសំរាប់កាត់បន្ថយការប៉ះពាល់ទាំងនេះ និងសំរាប់បំលាស់ប្តូរលំនៅដ្ឋានផងដែរ ។
- ការប្រៀបធៀបការបញ្ចេញឧស្ម័នកាបូនិក ដែលប្រើប្រេងឥន្ធនៈ និងធ្យូងថ្មក្នុងការផលិតថាមពលអគ្គិសនីចំនួនដូចគ្នាទៅនឹងការបាត់បង់ការស្រូបកាបូននៃព្រៃឈើដែលប៉ះពាល់ដោយសារគំរោងវារីអគ្គិសនីនេះ ។ ការប្រើប្រេងឥន្ធនៈមាន ១.៥១ ដង និងធ្យូងថ្ម មាន ១.៦១ ដង បញ្ចេញឧស្ម័នកាបូនិកច្រើនជាង វារីអគ្គិសនីនេះ ។

## ៨. ហេតុប៉ះពាល់សំខាន់ៗ នៃប្រព័ន្ធខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥ kV

ផ្អែកទៅស្តង់ដាររបស់ក្រសួងឧស្សាហកម្ម ដែលបានកំណត់និងផ្អែកលើស្ថានភាពជាក់ស្តែងមួយចំនួនមូលដ្ឋាននៃការសិក្សាលើហេតុប៉ះពាល់ លើការសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ មានដូចខាងក្រោម :

- ការរស់នៅរបស់ប្រជាពលរដ្ឋ និងដើមឈើ កំពស់ខ្ពស់ជាង៣ម៉ែត្រ ស្ថិតនៅក្រោមខ្សែគន្លង គិតពីអក្ស័ នៃបង្គោលខ្សែចំលងអគ្គិសនី១៥ម៉ែត្រសងខាង ចាត់ទុកថាការរស់នៅរបស់ប្រជាពលរដ្ឋ និងដើមឈើនោះនឹងត្រូវប៉ះពាល់អវិជ្ជមានជាមួយសំណង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ខាងលើនេះ ។
- ចំពោះ ដីធ្លី ដែលចាត់ទុកមានការប៉ះពាល់អវិជ្ជមាន នោះគឺជាប្រភេទដី ដែលស្ថិតនៅទីតាំងសាងសង់បង្គោលភ្លើងក្នុងទំហំ ១៥ម x១៥ ម =២២៥ម² ។
- ចំពោះព្រៃសហគមន៍ចាត់ទុកជាការប៉ះពាល់ ដល់ចំណូលរបស់សមាជិកសហគមន៍នៃការរកប្រយោជន៍ពីព្រៃនេះគឺគិតទៅតាមគន្លងនៃខ្សែ១១៥ នេះជាហ.ត ។

ខ្សែនោះវាមានតួនាទីសំរាប់នាំចរន្តអគ្គិសនីពីអគារថាមពលនៃទំនប់ទី១ និងទី២មកផ្គត់ផ្គង់ឱ្យអនុស្ថានីយ៍អូរសោម ។ ផលប៉ះពាល់អវិជ្ជមានដែលនឹងកើតចេញពីសកម្មភាពគំរោងតាមដំណាក់កាលនិមួយៗមានពណ៌នាតាមលំដាប់លំដោយខាងក្រោមនេះ:

Draft

ក. ដំណាក់កាលមុនសាងសង់គំរោង ( រចនាគំរោង)

- អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ដែលស្ថិតនៅក្នុងតំបន់ព្រៃការពារភ្នំក្រវាញ និងព្រៃកាពារដងទង់បន្តិចបន្តួចដែរ ដោយសារសកម្មភាពសិក្សាដូចជាមានសំឡេងអ៊ូអរក្នុងការត្រួសត្រាយព្រៃធ្វើដំណើរក្នុងការសិក្សា។
- អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោងដោយសារ ការត្រួសត្រាយ ព្រៃ និងសំឡេងអ៊ូអររបស់បុគ្គលិក-កម្មករក្នុងការធ្វើដំណើរសិក្សា នៅចំណុចអនុស្ថានីយ៍អូរសោម និងនៅតាមទីតាំងមួយចំនួនតាមគន្លងខ្សែបញ្ជូនតង់ស្យុងខ្ពស់១១៥គ.វ៉ ពីអគារថាមពលមកអនុស្ថានីយ៍អូរសោម ។
- ប្រជាជននៅក្នុងតំបន់មានការភយ័ខ្លាច មានគ្រោះថ្នាក់ដោយចរន្តអគ្គិសនី និងខ្លាចរលំបង្គោលភ្លើង ឬដាច់ខ្សែភ្លើងនាំឱ្យ ពួកគេងាយចាញ់បោកជនឱកាសនិយមធ្វើឱ្យគាត់មិនគិតប្រកបរធ្វើស្រែ ចំការនាំឱ្យបាត់ចំណូលរបស់គាត់។

**ខ. ដំណាក់កាលសាងសង់គំរោង**

ក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលមួយមានរយៈពេលរហូតដល់៤៨ខែ( យោងតាមរបាយការណ៍របស់ក្រុមហ៊ុន) ហើយសកម្មភាពការងារ នឹងអាចបង្កឱ្យមានការប៉ះពាល់អវិជ្ជមានសំខាន់ៗមួយចំនួនមានដូចតទៅ :

- នៅក្នុងដំណាក់នៃការសាងសង់គំរោងនេះអាចនឹងបណ្តាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងគំរោងដោយសារសកម្មភាពឈូសឆាយ និងពង្រាបដីស្រទាប់លើដែលអាចនាំឱ្យមានការហូរច្រោះទៀតផង ។
- ដំណាក់កាលសាងសង់មានផលប៉ះពាល់ជាមធ្យម ដែលបណ្តាលមកពីការហូរច្រោះដី ដោយសារការឈូសឆាយដីស្រទាប់លើដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង (បង្គោលភ្លើង និងអនុស្ថានីយ៍ដោយសារការធ្វេសប្រហែសមិនគោរពតាមបទដ្ឋានការងារដី ដែលធ្វើឱ្យមានការហូរច្រោះដី ពិសេសនៅរដូវវស្សា ។
- ប៉ះពាល់ជាមធ្យមដល់គុណភាពទឹកអូរ ស្ទឹងដោយសារការសាងសង់បង្គោលខ្សែ និង ការងារសាងសង់ដទៃទៀតបណ្តាលមកពីការខួង ឬការងារដី ការងារបេតុង និងការងារគ្រឹះដោយសារការដ្ឋានសាងសង់នេះស្ថិតនៅជិតប្រភពទឹកទាំងនោះ ។
- មានការបំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើមឈើ កំទេចឈើដើម្បីសំអាតការដ្ឋាន និងនៅតាមគន្លងខ្សែហើយផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសម្ភារៈសំរាប់ការងារសាងសង់ និងការហុយធូលីដីពីមធ្យោបាយដឹកជញ្ជូនទាំងនេះរបស់គំរោង។
- ការខួង ឬការងារដី ការងារបេតុង និងការងារគ្រឹះដែលការដ្ឋានសាងសង់បង្គោលភ្លើង និងធ្វើឱ្យខូចគុណភាពទឹកប្រឡាយ -អូរ-ស្ទឹងស្ថិតនៅជិតនោះ ។
- មានការបំពុលដី ដោយសារការកំពប់នៃប្រេងឥន្ធនៈ ការកំពប់នៃសារធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដីដូចជា: កាកសំណល់ចេញពី ឬលេចធ្លាយពីគ្រឿងចក្រ និងរថយន្តគ្រប់ប្រភេទក្នុងដំណើរការគំរោងនេះព្រមទាំងកាកសំណល់ចេញពីផ្ទះបាយផងដែរ ។
- ប៉ះពាល់ជាមធ្យមដល់គុណភាពទឹក អូរ ស្ទឹង នៅក្បែរការស្ថានសាងសាង់ បង្គោលភ្លើង និងអនុស្ថានីយ៍អូរសោមរបស់គំរោង ដោយសារការងារដី ការងារបេតុងដែលមានដីស្អុយ( ដីដែលជីកពីស្រទាប់ក្រោមគ្មានជីជាតិ) ហូរច្រោះដោយសារភ្លៀង និងការកំពប់នូវសម្ភារៈសំណង់ធ្វើឱ្យល្អក់ទឹកបណ្តាលឱ្យពុលដល់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹកនៃអូរ និងស្ទឹងទាំងនេះ ។

-

- អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោងដែលស្ថិតនៅក្នុងតំបន់ព្រៃការពារភ្នំក្រវាញ និងព្រៃការពារដងទង់បន្តិចបន្តួចដែរ ដោយសារសកម្មភាពសាងសង់ដូចជាមានសំឡេងអ៊ូអរក្នុងការកាប់ឈើតាមគន្លងខ្សែ
- ប៉ះពាល់ខ្លាំងទៅលើផ្ទៃដីសរុប ៤៨.៤៤ ហ.ត ក្នុងនោះប៉ះពាល់ដីព្រៃសរុប ៤៥.៣០ ហ.ត ដែលមានព្រៃស្រោងចំនួន ៤០.០៣ ហ.ត និងព្រៃល្បាយឫស្សីចំនួន ៥.២៧ ហ.ត ដោយសារការសាងសង់ បង្គោលភ្លើង និងខ្សែបញ្ជូនតង់ស្យុងខ្ពស់១១៥ គ.វ ពីអគារថាមពលទី១ និងទី២ មកអនុស្ថានីយ៍អូរសោម ។
- ប្រជាពលរដ្ឋនៅតាមគន្លងខ្សែចម្លងមានការភយ័ខ្លាចពីសុវត្ថិភាព ដោយខ្លាចឆក់ និងមានគ្រោះថ្នាក់ដោយសារ ចរន្តអគ្គិសនី និងរលំបង្គោលភ្លើង ។
- ប៉ះពាល់ដល់កន្លែងសក្ការៈបូជាទាំងឡាយដូចជា ព្រៃអ្នកតាឬទីទួល ព្រៃកប់ខ្មោចសំណាក់ម្ចាស់ទឹកដីក្នុងតំបន់ ។ល។ ដោយសារគំរោងធ្វើការកាប់ឆ្ការដីព្រៃឈើ ដើម្បីសាងសង់ ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ។
- អាចនឹងប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ក្នុងតំបន់គំរោងនេះ ដោយសារសកម្មភាពសាងសង់គំរោង និងការដឹកញ្ជូនឧបករណ៍-សំភារៈបរិក្ខាអគ្គិសនីដែលមានទំងន់រាប់តោនចូលទៅទីតាំងគំរោង បណ្តាលឱ្យមានការស្រុត ឬខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវដែលមានចំណោទឡើងទួល និងផ្លូវកោង ។ ល ។
- អាចបង្កឱ្យមានការប៉ះពាល់ដល់សុខមាលភាពបុគ្គលិក-កម្មករ របស់ក្រុមហ៊ុន និងប្រជាពលរដ្ឋមួយចំនួនចូលទៅតំបន់គំរោង ដោយសារធូលីដី ធូលីសីម៉ងត៍ ចំហាយចេញពីការប្រើប្រាស់សារធាតុគីមីជាដើម ។
- អាចនឹងមានការប៉ះពាល់ដល់សោភ័ណ្ឌភាពទេសភាពក្នុងតំបន់គំរោង ដោយសារការដំឡើងបង្គោលមិនមានការរត់ត្រង់គ្នា ឬកំពស់មិនស្មើគ្នាជាដើម ។ល។
- អាចនឹងកើតមានការផ្ទុះសំភារៈ គ្រឿងផ្ទុះ ឆេះប្រេង ឥន្ធនៈ នៅកន្លែងឬឃ្លាំងស្តុករបស់គំរោង និងការឆេះព្រៃក្នុងតំបន់គំរោង ដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេវរកម្មបង្កឡើង ។

## គ. ដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះគឺជាដំណាក់កាលមួយមានរយៈពេលវែងជាងគេរហូតដល់៣០ឆ្នាំ យោងតាមកិច្ចសន្យាស្នើសុំរបស់ក្រុមហ៊ុនដាក់ជូនទៅរាជរដ្ឋាភិបាល ។ សកម្មភាពគំរោងក្នុងដំណាក់កាលនេះ អាចនឹងបង្កឱ្យមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដូចតទៅ :

- អាចនឹងប៉ះពាល់គុណភាពទឹកលើដី និងក្រោមដីដោយសារការប្រើប្រាស់សារធាតុគីមីដើម្បីបង្អាក់កាលូតរបស់ដើម ឈើក្នុងពេលដំណើរការគំរោងនេះ ។
- ការងារដី និងការងារបេតុង បណ្តាលឱ្យមានការហូរច្រោះដោយសារ ទឹកភ្លៀង និងការបោះចោលនូវសម្ភារសំណង់ ធ្វើឱ្យមានការប៉ះពាល់ដល់កត្តាជីវសាស្ត្រ និងមច្ឆជាតិដែលរស់នៅក្នុងទឹកប្រឡាយ-អូរ-ស្ទឹងនៅក្បែរការដ្ឋានសាងសង់បណ្តាញអគ្គិសនី និងបង្គោលភ្លើង ។
- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំនេះប៉ះពាល់ជាមធ្យមដល់ធនធានព្រៃឈើដែលជាជំរកសត្វព្រៃច្រើនប្រភេទ ដូចមានចែងក្នុងជំពូក ៥ចំណុច ៥.១.២.១ដោយសកម្មភាពកាប់សំអាតមែក ឬដើមឈើតាមគន្លងខ្សែនេះ ដោយមិនឱ្យខ្ពស់ជាង ៣មដែលជាការរំខានផ្អើលសត្វផងដែរ ។

- ប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់គំរោង ដោយសារក្រុមហ៊ុននាំយកបុគ្គលិក-កម្មករគំរោងមកពីតំបន់ផ្សេងទៀត ឬជនបរទេស ។
- អាចនឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់បុគ្គលិក-កម្មករគំរោង ដោយនៅតំបន់គំរោងពុំទាន់មានប្រពន្ធ័ ផ្គត់ផ្គង់ទឹកស្អាតទេ ។
- ការកកចង្អៀតលើដងផ្លូវ និងបង្កឱ្យមានគ្រោះថ្នាក់ដោយសារសកម្មភាពថែទាំគំរោង និងការធ្វេសប្រហែសក្នុងការបើកបររបស់បុគ្គលិក-កម្មករគំរោង ។
- មានការប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ដោយសារបុគ្គលិក-កម្មកររបស់ ក្រុមហ៊ុនអាចចម្លងជំងឺផ្សេង១ដល់អ្នកភូមិ ដូចជាជំងឺអេដស៍ ជំងឺកាមរោគ ។ល ។

**ឃ. ដំណាក់កាលបិទគំរោង**

ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុនរបស់ប្រទេសចិន នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគំរោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាអ្នកសំរេចខ្លួនឯង ហើយសង្ឃឹមថាក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុនចិននេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ដែលគួរឱ្យកត់សំគាល់ឡើយ ។

## ៩. ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់គំរោង

នៅក្នុងជំពូកនេះគឺ រៀបរាប់អំពីផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) ដែលនឹងត្រូវអនុវត្តតាមដំណាក់កាលរបស់គំរោងជាពិសេសក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិថែទាំគំរោង និងបញ្ចប់គំរោង។ គោលបំណងសំខាន់នៃ ផ.គ.បនេះគឺត្រួតពិនិត្យតាមដាននូវការអនុវត្តន៏វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលបានចែងក្នុងជំពូកទី ៧ ។

ការអនុវត្តន៏ ផ.គ.ប នេះជាភារកិច្ចរបស់ក្រុមចំរុះ ដែលមានការចូលរួមពីការិយាល័យ, មន្ទីរ , ក្រសួងដែលពាក់ព័ន្ធដែលនឹងត្រូវបង្កើតឡើងដោយម្ចាស់គំរោងរួមជាមួយក្រសួងបរិស្ថាន។ ក្រុមត្រួតពិនិត្យនិងការឃ្លាំមើលវិធានការការពារបរិស្ថាននេះនិងក្រោមការត្រួតពិនិត្យ និងតាមដានពីក្រសួងបរិស្ថាន ។

យោងតាមអនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង យោងតាមលទ្ធផលនៃការសិក្សា ការវាយតំលៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គមដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាលរបស់គំរោង ដូចបានរៀបរាប់នៅក្នុងជំពូកទី ៥ម្ចាស់គំរោងនឹងរៀបចំកំណត់នូវវិធានការសំខាន់១មួយចំនួនសំរាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះ ដោយប្រសិទ្ធិភាពស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថានព្រមទាំងធានាឱ្យគំរោងអភិវឌ្ឍន៏ប្រកបដោយស្ថេរភាពដែលក្នុងនោះរួមមាន :

- ការរៀបចំផ្នែក ឬ ក្រុមទទួលខុសត្រូវសំរាប់ការអនុវត្តន៏ផែនការការងារ ។
- កំណត់ពេលវេលាធ្វើការងារឱ្យច្បាស់លាស់ ក្នុងកិច្ចការការពារបរិស្ថាន ។
- បំពាក់ឧបករណ៏ការពារសុខភាព គ្រោះថ្នាក់ និងគ្រឿងចក្រទំនើប១តាមបែបផែនបច្ចេកទេស ។
- ការពារ និងបង្ការជំងឺរាតត្បាតផ្សេង១ ។
- ការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់សារធាតុពុល ។
- ការធ្វើកន្លែងទុកសំណល់រឹង ។
- ជំរុញឱ្យមានការដាំដើមឈើ នៅទីសាធារណៈ ឬតំបន់ជុំវិញតំបន់ការពារទាំងនោះ ។



Draft

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំងបច្ចេកទេស និងទទួលយកនូវការកែប្រែបច្ចេក ទេសណាមួយ ដែលជំនាញតម្រូវឱ្យធ្វើ ។
- ធ្វើការអភិរក្ស ប្រភេទសត្វព្រៃសំខាន់ៗដែលធ្លាប់មាននៅតំបន់គំរោង ។
- ធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំអំពីប្រភេទព្រៃឈើ និងពពួកសត្វព្រៃ ដែលត្រូវអភិរក្សក្នុងតំបន់គំរោង ។
- ធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំ វិធីសាស្ត្រការពារសុខភាព អនាម័យ-សុវត្ថិភាពការងារ ។
- ត្រៀមថវិកាបំរុងទុកសំរាប់ប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន ។

__បញ្ជាក់:__- តំលៃនៃការស្តាបរិស្ថាននោះមានតំលៃ ៣.០៩១.២៥០.០០ ដុល្លារអាមេរិក ដូចបានរៀបរាប់ក្នុងជំពូកទី ៩ ហើយការស្តារបរិស្ថាននេះគឺមានរយៈពេល៦ខែធ្វើឱ្យការប៉ះពាល់បរិស្ថានដូចបានរៀបរាប់ក្នុងរបាយការណ៍អាចជួលជុលឡើងវិញ មើលតារាងទី ៧១ ទំព័រ ៣៣៧ (ដល់នៅឆ្នាំទី ៦ គំរោងអាចចំណេញវិញ) ។ ក្នុងនោះថវិកាសំរាប់ការរក្សាគុណភាពទឹក និងដីចំនួន ១.៩៧៧.២៤៨.០០ ដុល្លារអាមេរិក, ថវិកាសំរាប់ការពារបរិយាកាសបរិស្ថានចំនួន ៣៥.២០០.០០ដុល្លារអាមេរិក, ថវិកាសំរាប់ការពារសត្វព្រៃចំនួន៩៤៥.២០០.០០ដុល្លារអាមេរិក, ថវិកាសំរាប់ស្តារដែនសត្វព្រៃឡើងវិញចំនួន ៤០.០០០.០០ ដុល្លារអាមេរិក, ថវិកាសំរាប់ការពារសុខភាពចំនួន ៦៦.៤០០.០០ដុល្លារអាមេរិក, ថវិកាសំរាប់ការអប់រំបរិស្ថានចំនួន ៥០.០០០.០០ ដុល្លារអាមេរិក, ថវិកាសំរាប់ជួលការពិគ្រោះយោបល់ចំនួន ១០០.០០០.០០ ដុល្លារអាមេរិក, តំលៃសំណង និងការផ្លាស់ប្តូរទីលំនៅចំនួន ១៣០.០០០ដុល្លារអាមេរិក ឬយ៉ាងណា។

## ១០. ការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន

ការវាយតំលៃបរិស្ថាន និងសង្គមលើគំរោងវិនិយោគសំរាប់អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងអាតៃខេត្តពោធិ៍សាត់ រួមមានតំលៃបរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងបរិស្ថានសង្គម ដើម្បីរកឱ្យឃើញថា គំរោងត្រូវបំពេញបន្ថែមនូវតំលៃនៃការស្តារបរិស្ថានលើការវិនិយោគនេះ ។

- តម្លៃសេដ្ឋកិច្ចនៃការបាត់បង់ព្រៃឈើក្នុងតំបន់គំរោងសរុប ចំនួន ១.៥២៧.៨១៥ ដុល្លារអាមេរិក
- តម្លៃសេដ្ឋកិច្ចនៃការបាត់បង់ជលផល សរុបចំនួន ២៤.២០៦ដុល្លារអាមេរិក
- តម្លៃសំរាប់សំណងលើផលប៉ះពាល់ដោយសារគំរោង សរុប ចំនួន ១២៥.៨១០ ដុល្លារអាមេរិក

## ១១.១ សន្និដ្ឋាន និងអនុសាសន៍

### សន្និដ្ឋាន

ការវាយតំលៃបរិស្ថាន និងសង្គមលើគំរោងវារីអគ្គិសនីអាតៃ ខេត្តពោធិ៍សាត់ អាចធ្វើសេចក្តីសន្និដ្ឋានដូចតទៅ :

- ការវិនិយោគគំរោងនេះសរុបចំនួន ២៤៦.៨៨៥.៦០០ (ពីររយសែសិបប្រាំមួយលាន ប្រាំបីរយប៉ែតសិបប្រាំពាន់ប្រាំមួយរយ) ដុល្លាអាមេរិកគឺ១ MW ស្មើនឹង ២.០៥៧.៣៨០ (ពីរលាន ហាសិបប្រាំពីរពាន់បីរយប៉ែតសិប) ដុល្លាអាមេរិក និងតំលៃអគ្គិសនីក្នុង ១គីឞ គឺ ០.០៧១៤ ដុល្លារអាមេរិក។ ផ្អែកតាមបានចុះកិច្ចសន្យាអនុវត្តគំរោងរវាងក្រុមហ៊ុននេះ និងរាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ ។
- គំរោងសាងសង់របស់គំរោងនេះធ្វើឱ្យមានប៉ះពាល់ផ្ទៃដីព្រៃសរុប ៤.១៨៧.៨១ ហ.ត ក្នុងនោះការប៉ះពាល់ដោយសារការសាងសង់អាងទាំងពីរ(តំបន់១) ៣.៨៦៩.១៧ ហ.ត. ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី (តំបន់២) ២៧៣.៣៤ ហ.ត និងការសាងសង់ខ្សែបញ្ជូនចរន្ត១១៥គ.វ(តំបន់៣) ចំនួន៤៥.៣០ហ.ត។

- នៅក្នុងតំបន់គំរោង ក្រុមការងារបានរកឃើញពពួកសត្វព្រៃរួមមាន : ថនិកសត្វចំនួន ៥០ប្រភេទ បក្សី ១៣០ ប្រភេទ ឧរុង្គសត្វ ៣៦ប្រភេទ មច្ឆជាតិ២១ប្រភេទរស់នៅ។
- ការសាងសង់អាងទី១ ធ្វើឱ្យមានការប៉ះពាល់ដល់ដីប្រើប្រាស់របស់ប្រជាពលរដ្ឋចំនួន ៣៧ គ្រួសារ ដែលមានដីកសិកម្ម (ស្រែនិងចំការ) ១៨.៩ ហ.ត. ដីបុស្ស ១៦.៧២ហ.ត. ដីកប់សព ២.៤៦ហ.ត ដីសហគមន៍ព្រៃការពារក្រវាញ ឃុំអូរសោម ២៧.៦១ ហ.ត។
- ការប្រៀបធៀបធារទឹកនៅទីតាំងទំនប់ទី២ ឃើញថាមានកំរិតខ្ពស់ជាងធាទឹកនៅទីតាំងទំនប់ទី២មកអគារថាមពលទី២ ដែលមានកំរិតធាទឹកមធ្យម នៅរដូវវស្សាចន្លោះ ពីខែកក្កដា-កញ្ញា ឆ្នាំ២០០៧ គឺ ៥.៤១ ម$^{៣}$.ស នៅឆ្នាំ២០០៨ គឺ២.២៩ ម$^{៣}$.ស កំរិតធាទឹកអតិបរមា ក្នុងឆ្នាំ២០០៧ នៅខែ កក្កដា គឺ៤២.៥៥ម$^{៣}$.ស កំរិតធាទឹកអតិបរមាក្នុងឆ្នាំ ២០០៨ នៅខែមិថុនា គឺ៩.៩៧ ម$^{៣}$.ស កំរិតធាទឹកអប្បបរមានៅរដូវប្រាំងពីខែវិច្ឆិកា ដល់ខែ មេសា ឆ្នាំ២០០៧ -២០០៨ គឺ ០.០៥ ម$^{៣}$.ស កំរិតធាទឹកមធ្យម ០.៥១ ម$^{៣}$.ស។
- ប្រភពទឹកលើដី(អូរស្ទឹង) និងទឹកក្រោមដីក្នុងតំបន់គំរោងមានការបំពុលពីសកម្មភាពរបស់មនុស្សជាមធ្យម។ ចំពោះការបំពុលដោយសារធាតុគីមីវិញមានតិចតួចប៉ុណ្ណោះ ទោះបីជាមានប៉ារ៉ាម៉ែត្រមួយចំនួនលើសពីស្តង់ដាគុណភាពទឹករបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវសាស្រ្តចំរុះរបស់ក្រសួងបរិស្ថានក៏ដោយ ព្រោះវាកើតចេញពីធម្មជាតិក្នុងតំបន់គំរោង និងមានមនុស្សរស់នៅច្រើនក្នុងពេលសាងសង់គំរោងតែប៉ុណោះ។
- គំរោងនេះពុំមានហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថាន និងសង្គមទេប្រសិនបើក្រុមហ៊ុនអនុវត្តទៅតាមវិធានការកាត់បន្ថយនូវការប៉ះពាល់អវិជ្ជមានឱ្យដល់កំរិតអប្បបរមានេះ ម្យ៉ាងទៀតក្រុមហ៊ុនមានបទពិសោធន៍ ជាច្រើនឆ្នាំនៅប្រទេសចិន និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនទៀតក្នុងការគ្រោង និងរចនាគំរោងនេះ។ ក្រុមហ៊ុនបំពាក់ឧបករណ៍សំអាតទឹកកខ្វក់ ត្រូវសហការជាមួយក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងផ្តល់យោបល់ (មានលំអិតនៅក្នុងជំពូកទី៧)។
- តាមរយៈគំរោងនេះបានផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ ដូចជាក្នុងដំណាក់កាលសាងសង់គំរោងត្រូវជ្រើសរើស បុគ្គលិក-កម្មករគំរោងរហូតដល់ ៩០០នាក់ ក្នុងនោះ ប្រជាពលរដ្ឋក្នុងមូលដ្ឋានចំនួន៥០០នាក់។ រីឯក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង នឹងត្រូវជ្រើសរើសបុគ្គលិក-កម្មករ ចំនួន៣០នាក់ក្នុងនោះ ប្រជាពលរដ្ឋ មូលដ្ឋាន សរុប១៩នាក់។

**អនុសាសន៍**

ដើម្បីទទួលបានភាពរលូនក្នុងការ អនុវឌ្ឍន៍គំរោងវារីអគ្គិសនីស្ទឹងអាតៃ និងពង្រឹងភាពទទួលខុសត្រូវចំពោះកិច្ចអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពលើធនធានធម្មជាតិ និងសុវត្ថិភាពសង្គម នោះតាមរយៈការសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមសំរាប់គំរោងវារីអគ្គិសនីនេះ **SAWAC** សូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដូចតទៅ -:

- ក្រុមហ៊ុនត្រូវធានាថាគុណភាពសំណង់ទំនប់ទាំងពីរ នៃវារីអគ្គិសនីនេះអាយុកាលរបស់បេតុងគឺ ១០០ ឆ្នាំ។
- មុននឹងដំណើរការគំរោង ត្រូវធ្វើការសាកល្បង ឬធ្វើតេស្តរាល់សំណង់ទំនប់ ទូនេល ទួប៊ីន ជាដើម។ល។ ដោយជឿជាក់ថាគ្រប់រាល់សំណង់ទាំងនោះ គ្មានការលេចជ្រាប ឬជិតល្អដំណើរការបានល្អដល់អាយុកាលដែលបានកំណត់ក្នុងការគ្រោងរចនាគំរោង ឬតាមសៀវភៅបន្ទុក ឬតាមកាតាឡុក។ បើមានការខុសពីប្រក្រតីត្រូវធ្វើការជួសជុលជាបន្ទាន់ ឬសង់ឡើងវិញ ឬប្តូរជាថ្មីវិញ។

Draft

- ក្រុមហ៊ុនគួរធ្វើកិច្ចសហការជាមួយរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងពាក់ព័ន្ធ ត្រូវលើកផ្លាកប្លាន់ណូ ហាមឃាត់ការកាប់ឈើ ការបាញ់សត្វព្រៃ ការលុកលុយរកក្រញូង ការចាប់ដីធ្វើកម្មសិទ្ធិខុសច្បាប់ ក្នុងតំបន់ព្រៃការពារភ្នំក្រវាញកណ្តាល ព្រៃការពារដងទង់ និងតំបន់ការពារដែនជំរកសត្វព្រៃភ្នំសំកុសឱ្យបានច្រើនកន្លែង
- ក្រុមហ៊ុនគប្បីធ្វើសហប្រតិបត្តិការយ៉ាងពេញទំហឹង (ទាំងថវិកា និងបច្ចេកទេស) ជាមួយរដ្ឋបាលព្រៃឈើ . អង្គការ ជី . អង្គការ FFI. ក្រសួងបរិស្ថាន . និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការអភិរក្សព្រៃឈើដើម្បីស្តារព្រៃឈើឡើងវិញក្នុងតំបន់ក្បែរខាង និងទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីព្រៃឈើធ្វើជាកម្មសិទ្ធិតាមរយៈការបង្កើតជាសហគមន៍ការពារព្រៃឈើតាមដងផ្លូវចេញចូលតំបន់គំរោងទាំងនោះបានន័យថា គំរោងបានរួមចំណែកស្តារឡើងវិញនូវការបាត់បង់ព្រៃឈើ និងជាជំរកសត្វព្រៃ ហើយធ្វើឱ្យមានលំនឹងបរិស្ថាននៃការអភិរក្សភ្នំក្រវាញកណ្តាល ព្រៃការពារដងទង់ និងដែនជំរកសត្វព្រៃភ្នំសំកុសនេះទៀតផង ។
- រាល់ដំណាក់កាលនៃគំរោងក្រុមហ៊ុនគួរតែអនុវត្តទៅតាមច្បាប់ដែលពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជាដើម្បីឱ្យគំរោងប្រកបទៅដោយជោគជ័យ និងមាននិរន្តរភាពទៅតាមសង្គមកម្ពុជា។

## ១១.២ សន្និដ្ឋាន និងអនុសាសន៍លើគំរោងវារីអគ្គិសនីស្ទឹងអាតៃ (ផ្នែកប្រព័ន្ធខ្សែចម្លង)

### សន្និដ្ឋាន ផ្នែកប្រព័ន្ធខ្សែចម្លង

ការវាយតំលៃបរិស្ថាន និងសង្គមលើគំរោងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គ.វ ពីរខ្សែពីអគារថាមពលទី១-អនុស្ថានីយអូរសោម និងពីអគាថាមពលទី២-អនុស្ថានីយអូរសោម អាចធ្វើសេចក្តីសន្និដ្ឋានដូចតទៅ :

- ខ្សែទី១គឺពីអគារថាមពលទី១- អនុស្ថានីយអូរសោមមានប្រវែង៤.១២គ.ម និងមានបង្គោលចំនួន១១។ ខ្សែទី២គឺពីអគារថាមពលទី២-អនុស្ថានីយអូរសោមមានប្រវែង ១៣.៤៥គ.ម និងមានបង្គោលចំនួន ៣៣។
- ទុនវិនិយោគសំរាប់ប្រព័ន្ធខ្សែចម្លង ៣.៤៨២.៧០០ (បីលាន បួនរយប៉ែបសិបពីរពាន់ ប្រាំពីររយ) ដុល្លារអាមេរិក។ ការវិយោគលើប្រព័ន្ធខ្សែចម្លងនេះរួមមាន: ខ្សែចម្លងតង់ស្យុងខ្ពស់ ១១៥ គ.វ ពីអគារថាមពលទី១ ដល់អនុស្ថានីយអូរសោមចំនួន៧៣៩.៥០០.០០ដុល្លារអាមេរិក. ខ្សែចម្លងតង់ស្យុងខ្ពស់១១៥ គ.វពីអគារថាមពលទី២ ដល់អនុស្ថានីយ អូរសោមចំនួន ២.៧៤៣.២០០,០០ ដុល្លារអាមេរិក។
- គំរោងខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់នេះអាចនឹងមានហានិភ័យកំរិតខ្ពស់ដូចជា ការបាក់រលំបង្គោល និងដាច់ខ្សែភ្លើងជាដើម ដោយសារគ្រោះធម្មជាតិក្នុងពេលសាងសង់ និងពេលដំណើរការ ដូចមានរៀបរាប់លំអិតក្នុងជំពូក៨ នៃរបាយការណ៏នេះ ។
- តាមរយៈគំរោងនេះផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ ដូចជាក្នុងដំណាក់កាលសាងសង់បុគ្គលិក-កម្មករគំរោងត្រូវជ្រើសរើសបុគ្គលិក-កម្មករសរុប៥២នាក់ ក្នុងនោះកម្មករជាប្រជាពលរដ្ឋមូលដ្ឋានសរុប៤០នាក់ ។ រីឯនៅដំណាក់កាលប្រតិបត្តិការនិងថែទាំគំរោង ក្រុមហ៊ុនមានភារកិច្ចទទួលខុសត្រូវខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គ.វ ដោយត្រូវការអ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវតាមផ្នែកជំនាញសរុបចំនួន១២នាក់ ក្នុងនោះបុគ្គលិកកម្ពុជាចំនួន ០២នាក់។

- ក្រុមហ៊ុននឹងផ្ទេរទៅឱ្យក្រុមហ៊ុនអគ្គិសនីកម្ពុជាជាអ្នកទទួលខុសត្រូវ និងគ្រប់គ្រងបន្តតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ តាមរយៈការផ្ទេរនេះនឹងធ្វើឱ្យមានការផ្តល់ការងារធ្វើដល់បុគ្គលិក.វិស្វករកម្ពុជាថែមទៀត ក្នុងដំណាក់ការប្រតិបត្តិ និងថែទាំគំរោងក្នុងរយៈពេល៣០ឆ្នាំខាងមុខនេះ ។

## អនុសាសន៍ ផ្នែកប្រព័ន្ធខ្សែបញ្ជូនចរន្ត

ដើម្បីទទួលបានភាពរលូនក្នុងការអនុវត្តន៍គំរោង BOT នៃការសាងសង់ប្រពន្ធ័បណ្តាញខ្សែបញ្ជូនចរន្តអគ្គិសនីតង់ស្យុងខ្ពស់១១៥ និងពង្រឹងភាពទទួលខុសត្រូវចំពោះកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាពលើធនធានធម្មជាតិ និង សុវត្ថិភាព សង្គម នោះតាមរយៈការសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមសំរាប់គំរោងនេះ SAWAC សូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដូចតទៅ -:

- ក្រុមហ៊ុនត្រូវរៀបចំសហការជាមួយអាជ្ញាធរដែនដីដើម្បីដាក់ផ្លាកធំៗ អំពីសេចក្តីជូនដំណឹងអំពីចំណីខ្សែ១១៥គ.វ និងការសាងសង់សំណង់ផ្សេងៗ រួមទាំងការដំណាំផ្សេងៗនៅក្រោមគន្លងទឹង៣០ម.នៃខ្សែនេះឱ្យបានច្រើននៅតាមបង្គោលភ្លើង ។
- ក្រុមហ៊ុនគប្បីធ្វើសហប្រតិបត្តិការយ៉ាងពេញទំហឹង (ទាំងថវិកា និងបច្ចេកទេស) ជាមួយក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បដោះស្រាយនូវវិធានការបន្ធូរបន្ថយហេតុប៉ះពាល់បរិស្ថាននិងសង្គមដែលអាចកើតឡើងដោយថាហេតុដោយសារគ្រោះធម្មជាតិផ្សេងៗ ។
- ក្រុមហ៊ុនគប្បីសហការជាមួយអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធដើម្បីជួសជុលផ្លូវ. លូ. ស្ពានដែលខូចខាតដោយការដឹកសម្ភារសំណង់របស់ខ្លួន ។
- ក្រុមហ៊ុនគប្បីធ្វើការចុះត្រួតពិនិត្យបណ្តាញជាប្រចាំអំពីសុវត្ថិភាពតាមគន្លងខ្សែនេះ ដូចជាកំពស់ដើមឈើមិនឱ្យលើសពី៣ម គ្មានសំណង់ផ្សេងៗក្រោមគន្លងខ្សែដើម្បីជៀសវាងការប៉ះពាល់ដល់សុខភាពសុវត្ថិភាពរបស់ប្រជាពលរដ្ឋរួមទាំងសត្វផងដែរ ។
- ក្រុមហ៊ុនគប្បីសហការជាមួយមន្ទីរពាក់ព័ន្ធដើម្បីពិនិត្យមើលខ្សែរឹតបង្គោលទៅគ្រឹះបង្គោល ដោយជឿជាក់ថាខ្សែទាំងនោះបានរឹតតឹងហើយពុំមានការបាត់បង់ឡើយ ។